ទស្សនាវដ្តី

ប្រជាជន

THE PRACHEACHUN MAGAZINE



ឆ្នាំទី២១ លេខ ២៥០ ខែមីនា ឆ្នាំ ២០២២

និពន្ធនាយក :
លោក តាក ស៊ុនអ៊ី
គណៈកម្មការនិពន្ធ
១. លោក ខៀវ ណាវី
២. លោក អ៊ឹម សុន្ធរៈ
៣. លោក វង្ស សាវុធ
៤. លោក ទាវ សារៈមុនី
៥. លោក សុខ សុធន
៦. លោក ងួន កុលបុត្រ
៧. លោក មាន សេរីរិត
លេខានិពន្ធ
១. លោក ស្វាយ ភីរុណ
២. លោក ម៉ក់ ឈិន
អ្នកបកប្រែភាសា
១. លោកស្រី មែន នារីសោភ័គ
អ្នកថតរូប
១. លោក សុផាត វីរៈមុនី
វិចិត្រករ
១. លោក ធា សាវុធ
អាស័យដ្ឋាន :
លេខ ២០៣
មហាវិថី ព្រះនរោត្តម
ភ្នំពេញ-កម្ពុជា
ទូរស័ព្ទលេខ :
០២៣ ២១៩ ០៦៥
Address :
No 203 Preah
Norodom Bld.
Phnom Penh Cambodia
Tel : 023 219 065

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ៖ *ទំនាក់ទំនងកម្ពុជា-ឡាវ ត្រូវបានលើកកម្ពស់ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ.....*

៧

ទំនាក់ទំនងនៃប្រទេសទាំងពីរកម្ពុជា-ជប៉ុន ស្ថិតក្នុងកម្រិតល្អបំផុតដែលពុំធ្លាប់មាន ....

៨

សម្តេចតេជោ ហ៊ុន សែន ៖ *យកចិត្តទុកដាក់អាទិភាពកំពូលរបស់យើងគឺសន្តិភាព....*

១០

សម្តេចក្រឡាហោម ស ខេង ៖ *យើងត្រូវផ្តោតលើអភិក្រម រួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ សំដៅទទួល .....*

១៤

សម្តេចពិជ័យសេនា ទៀ បាញ់ ៖ *ពង្រឹងស្មារតីសាមគ្គីភាព បន្តកាន់ទង់សន្តិភាពតកូនតចៅទៅមុខទៀត .....*

១៥

មាតិកា
Contents

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ***អូន ព័ន្ធមុនីរ័ត្ន*** *អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារ ស្នាក់ការគណបក្សខេត្តកណ្តាល*

១៦

ក្រុមមុខ : សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទទួលស្វាគមន៍ជាផ្លូវការ ដំណើរបំពេញទស្សនកិច្ចរបស់ឯកឧត្តម គីស៊ីដា ហ្វូមីអូ នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន

វិចារណកថា : គណបក្សប្រជាជនកម្ពុជា របស់ប្រជាជន ដោយសារប្រជាជន និងដើម្បី ០៣

Editorial : The Cambodian People's Party of the People, by the People, and for the ០៣

- *អត្ថបទនយោបាយ: សាលក្រមផ្តន្ទាទោសមេក្លោង និងបក្សពួកប៉ុនប៉ងធ្វើរដ្ឋប្រហារ គឺជាការ ០៦*
- *សកម្មភាពសមាជិក រដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស ១៧*
- *សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស ២១*
- *សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច ២៣*
- *"ការយោសនាបោះឆ្នោត" សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ២៥*
- *ធនាគារជាតិនៃកម្ពុជាកំណត់គោលនយោបាយចម្បងៗ ដើម្បីគាំទ្រការងើបឡើងនៃកំណើន ២៦*
- *វប្បធម៌ : ប្រវត្តិខេត្តកោះកុង ២៩*
- *ចំណេះដឹងទូទៅ : តើសេដ្ឋកិច្ចពិភពលោកទទួលរងឥទ្ធិពលយ៉ាងណា ពីសង្គ្រាម ៣០*
- *វិទ្យាសាស្ត្រ និងសុខភាព : ឧស្សាហ៍ឈឺក្បាល នៅពេលព្រឹកក្រោកពីគេង អាចជាមូលហេតុនៃ ៣១*
- *កំណាព្យ: បណ្តាំឆ្នាំឆ្លូវទៅឆ្នាំខាល ..... សំណើច ៣២*

សូមប្រសិទ្ធពរបវរមហាប្រសើរជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណបក្សប្រជាជនកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសជ័យមហានក្ខត្តឫក្សនៃទិវាគម្រប់ជន្មាយុ ៧១ ឈានចូល ៧២ ឥស្សរបស់សម្តេច

យើងខ្ញុំសូមលំអោនកាយគោរពដោយក្តីដឹងគុណដ៏ជ្រាលជ្រៅបំផុត ***សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*** *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជាដែលបានលះបង់អស់កម្លាំងកាយកម្លាំងចិត្ត និងបញ្ញាញាណ ក្នុងការដឹកនាំប្រទេសឆ្លងកាត់ឧបសគ្គរាប់ម៉ឺនសែនជំពូក ប្រកបដោយគតិបណ្ឌិត ភាពឈ្លាសវៃ និងភាពអង់អាចក្លាហាន តាំងពីដំណាក់កាលសង្គ្រោះជាតិពីរបបប្រល័យពូជសាសន៍រហូតមកដល់បច្ចុប្បន្ននេះ សម្រេចបានសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រដ៏ថ្លៃថ្លាវិសេសវិសាលបំផុត ដែលបានធ្វើឲ្យប្រទេសជាតិមានសន្តិភាពពេញលេញ ឯកភាពជាតិ ឯកភាពទឹកដី និងមានការអភិវឌ្ឍលើគ្រប់វិស័យប្រជាជនមានសិទ្ធិសេរីភាពបរិបូរនិងរស់នៅយ៉ាងសុខដុមរមនាការពារយ៉ាងរឹងមាំនូវឯករាជ្យអធិបតេយ្យ និងបូរណភាព ទឹកដី ហើយកំពុងបន្តឈានទៅមុខយ៉ាងស្វាហាប់ លើមាគ៌ាសន្តិភាព និងប្រជាធិបតេយ្យ ឆ្ពោះទៅសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។*

សូមឧទ្ទិសបួងសួងគុណបុណ្យព្រះរតនត្រ័យ ទេវតាឆ្នាំថ្មី វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ព្រមទាំងតេជៈបារមីនៃវិញ្ញាណក្ខ័ន្ធរបស់បុព្វវីរបុរសខ្មែរគ្រប់ៗជំនាន់ សូមជួយប្រោះព្រំ គាំពារ ថែរក្សា ***សម្តេចអគ្គមហាសេនាបតីតេជោ*** *សម្រេចបានជោគជ័យ ធំៗថ្មីៗទៀត ក្នុងការដឹកនាំប្រទេសកម្ពុជា និងសូមគោរពជូនពរសម្តេចអគ្គមហាសេនាបតីតេជោ និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំង បុត្រា បុត្រី ចៅប្រុស ចៅស្រី បានប្រកបនូវពុទ្ធពរទាំង៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជារៀងដរាប ។*

គោរពជូនដោយក្តីកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត

ឧស្សាហដ្ឋីប្រជាជន

សួស្តីឆ្នាំថ្មី

ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ
ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

សូមប្រសិទ្ធពរ បវរសួស្តី សិរីមង្គល មហាប្រសើរ ថ្វាយ និងជូនសម្តេច ព្រះអង្គម្ចាស់ ឯកឧត្តមអ្នកឧកញ៉ា លោកជំទាវ លោក លោកស្រីមន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងនគរបាលជាតិ និងជនរួមជាតិនៅគ្រប់ទិសទី ព្រមទាំងអង្គទូត និងអង្គការអន្តរជាតិ នានា ដែលកំពុងបំពេញបេសកកម្មនៅព្រះរាជាណាចក្រកម្ពុជា សូមបានប្រកបតែនឹង សេចក្តីសុខ រីកចម្រើន ភាពសុខដុមរមនា ត្រជាក់ត្រជុំ ក្រោមម្លប់នៃសុខសន្តិភាព សុភមង្គល និងជោគជ័យជារៀងដរាប ។

គោរពជូនពរ

ទស្សនាវដ្តីប្រជាជន

វិចារណកថា
EDITORIAL

គណបក្សប្រជាជនកម្ពុជា របស់ប្រជាជន ដោយសារប្រជាជន និងដើម្បីប្រជាជន

The Cambodian People's Party of the People, by the People, and for the People

គណបក្សប្រជាជនកម្ពុជាបានចាប់បដិសន្ធិឡើង នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ ជាគណបក្សដែលកើតចេញពីចលនាតស៊ូ ស្នេហាជាតិរបស់ប្រជាជនកម្ពុជា បានបន្តអត្ថិភាពរហូតមកដល់ បច្ចុប្បន្ន ដោយសារការចូលរួមគាំទ្រយ៉ាងសកម្មពីសំណាក់ប្រជាជន កម្ពុជា ។ គណបក្សបានដឹកនាំប្រទេសជាតិឆ្លងកាត់ការលំបាកវាប់ មិនអស់ តាំងពីដំណាក់កាលតស៊ូប្រឆាំងអាណានិគមនិយមបារាំង ដណ្តើមបានឯករាជ្យជាតិ រំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ ធ្វើជាកម្លាំងស្នូលក្នុងការស្វះស្វែងរក សុខសន្តិភាព បង្កើតបានការឯកភាពជាតិ និងទឹកដី ផ្តល់ភាពអនុគ្រោះ យ៉ាងធំធេងដល់ការអភិវឌ្ឍប្រទេសជាតិ ឲ្យមានការរីកចម្រើន យ៉ាងខ្លាំងនាពេលបច្ចុប្បន្ន និងចុងក្រោយនេះ បានដឹកនាំប្រជាជន ឲ្យរួចចាកផុតគ្រោះភ័យនៃមហន្តរាយដោយសារជំងឺឆ្លងរាតត្បាត កូវីដ-១៩ ។ នៅក្នុងប្រវត្តិនៃការដឹកនាំប្រទេសជាតិគ្មានសភាពការណ៍ ណាមួយដែលគណបក្សប្រជាជនកម្ពុជា មិនធ្លាប់ឆ្លងកាត់ នោះទេ ប៉ុន្តែគណបក្សតែងទទួលបានជោគជ័យគ្រប់ពេលវេលា ។

ពិនិត្យឡើងវិញ ប្រវត្តិសាស្ត្រកម្ពុជាក្នុងរយៈពេលប្រមាណជាង ១០០ឆ្នាំចុងក្រោយ នៅពេលប្រទេសជាតិធ្លាក់ទៅក្នុងគ្រោះមហន្តរាយ ប្រឈមទៅនឹងការរលត់រលាយបាត់បង់ពូជសាសន៍ពីលើភពផែនដី ប្រសិនបើគ្មានវត្តមានគណបក្សប្រជាជនកម្ពុជា តើវាសនាប្រទេស ជាតិ និងប្រជាជនយើងទៅជាយ៉ាងណា ? គណបក្សប្រជាជនកម្ពុជា តែងតែបានជួយសង្គ្រោះប្រជាជនក្នុងគ្រាដែលលំបាកបំផុត ហើយ បានប្រកាន់ខ្ជាប់ឥតប្រែប្រួលនូវគោលបំណង និងឧត្តមគតិរបស់ខ្លួន គឺប្រមូលកម្លាំងជាតិទាំងមូលដែលមានឧត្តមគតិស្នេហាជាតិ មាតុភូមិ ស្រលាញ់លទ្ធិប្រជាធិបតេយ្យ និងសន្តិភាពដោយមិនប្រកាន់ហាន: ជីវភាព ជនជាតិ ជំនឿសាសនា អតីតកាល ដើម្បីរួមកម្លាំងគ្នាការពារ មាតុភូមិ ការពារសមិទ្ធផលសង្គមជាតិ និងកសាងប្រទេសកម្ពុជាមួយ ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ អព្យាក្រឹត្យ និង វឌ្ឍនភាពសង្គម ។ ជានិច្চកាលគណបក្សតែងឈរនៅខាងប្រជាជន រួមសុខរួមទុក្ខជាមួយ ប្រជាជន ពុះពារជម្នះគ្រប់ឧបសគ្គ ហ៊ានធ្វើ ពលិកម្មឥតរួញរា ដើម្បីសម្រេចបាននូវគោលបំណងដ៏ឧត្តុង្គឧត្តម ខាងលើនេះ ។

*តាមរយៈសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រ ដែលសម្រេចបាន ក្រោមការដឹកនាំរបស់គណបក្សប្រជាជនកម្ពុជា បានបង្ហាញឲ្យ ឃើញអំពីសមត្ថភាព ភាពក្លាហាន ការទទួលខុសត្រូវខ្ពស់ ភាពឈ្លាសវៃ ចក្ខុវិស័យវែងឆ្ងាយ និងស្មារតីតម្កល់ផលប្រយោជន៍ ជាតិ និងប្រជាជនធំលើសអ្វីៗទាំងអស់របស់ថ្នាក់ដឹកនាំគណបក្ស ប្រជាជនកម្ពុជា ដែលនៅក្នុងនោះ**សម្តេចអគ្គមហាសេនាបតីតេជោ***

The Cambodian People's Party was founded on June 28, 1951 as a party born of the patriotic movement of the Cambodian people and has continued to exist to this day thanks to the active support of the Cambodian people. The party has led the country through countless hardships since the French colonial struggle for independence, the overthrow of the genocidal regime of Pol Pot on January 7, 1979, and stayed as a core force in the search for peace. National and territorial unity has greatly contributed to the country's development and advancement, while recently led the people to escape the threat of the Covid-19 pandemic. In the history of leading the country, CPP has gone through every kind of situation and every time the party comes out successful.

Reviewing the history of Cambodia over the last 100 years, when the country fell into disaster, facing extinction on the planet, if there were no presence of the Cambodian People's Party, no one could have fathomed the fate of our nation and people. The Cambodian People's Party has always rescued the people in the most difficult times and has consistently adhered to its goals and ideals. It unites the whole nation with patriotic ideals and motherland, love for democracy and peace, regardless of status, livelihood, ethnicity, faiths, religions and past to join forces to protect the motherland, protect the achievements of the society and build a Cambodia of independence, peace, freedom, democracy, neutrality and social progress. The party always stands by the people, shares bad and good with the people, overcomes all obstacles, and dares to sacrifice relentlessly to achieve the above noble goals.

The great historic achievements under the leadership of the Cambodian People's Party reflected ability, courage, responsibility, intelligence, long-term vision and the spirit of upholding the interests of the nation and the people above all else. With the leaders of the Cambodian People's Party, Samdech Akka Moha Sena

ហ៊ុន សែន ប្រធានគណបក្ស និងជានាយករដ្ឋមន្ត្រី គឺជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើមនៃប្រជាជនកម្ពុជា និងជាស្នូលនៃគណបក្សប្រជាជនកម្ពុជា ។

គណបក្សប្រជាជនកម្ពុជា ជាគណបក្សដឹកនាំប្រទេស មានតួនាទីទទួលខុសត្រូវជោគវាសនាជាតិ និងប្រជាជនចំពោះមុខប្រវត្តិសាស្ត្រ។ នេះជាកាតព្វកិច្ចដ៏លំបាក ប៉ុន្តែថ្លៃថ្នូរខ្ពង់ខ្ពស់ ដែលឆ្លុះបញ្ចាំងឲ្យឃើញថា ការប្រគល់នូវការជឿទុកចិត្តរបស់ប្រជាជនមកលើការដឹកនាំរបស់គណបក្ស គឺដោយសារតែគណបក្សមានសមត្ថភាពគ្រប់គ្រាន់ មានធនធានមនុស្ស មានអ្នកដឹកនាំប្រកបដោយទេព-កោសល្យ និងតែងបានរួមសុខរួមទុក្ខជាមួយប្រជាជន ទោះបីស្ថិតក្នុងស្ថានភាពលំបាក ស្មុគស្មាញបែបណាក៏ដោយ ។ គណបក្សមានគោលការណ៍គោលនយោបាយ និងមានមាគ៌ាដឹកនាំច្បាស់លាស់នៅក្នុងគ្រប់សភាពការណ៍ទាំងអស់ ។ នៅក្នុងនយោបាយ និងសកម្មភាពទាំងមូលរបស់គណបក្ស តែងតែប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ចំពោះប្រជាជន និងយកប្រជាជនធ្វើជាគោលដៅនៃការបម្រើរបស់ខ្លួន ។ នៅគ្រប់កាលៈទេសៈ គណបក្សតែងតែអប់រំមន្ត្រីឲ្យធ្វើតែអំពើល្អ ផ្សារភ្ជាប់ជាមួយប្រជាជន ស្តាប់មតិយោបល់របស់ប្រជាជន មិនប្រព្រឹត្តអ្វីធ្វើឲ្យប៉ះពាល់ទៅដល់ផលប្រយោជន៍របស់ជាតិ និងប្រជាជន អប់រំបង្កើនមនសិការយល់ដឹងរបស់ប្រជាជន និងអប់រំបំផុសចលនារបស់ប្រជាជន ឲ្យចូលរួមអនុវត្តយ៉ាងសកម្មនូវកម្មវិធីនយោបាយរបស់គណបក្សដើម្បីកសាង និងការពារមាតុភូមិ។ គណបក្សក៏បានកំណត់ច្បាស់ថា ប្រជាជនជាកត្តាសម្រេច នៃជ័យជម្នះ និងជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ទ្រទ្រង់ដល់ការដឹកនាំប្រទេស ។ បើប្រជាជនមិនយល់ ប្រជាជនមិនគាំទ្រ និងមិនចូលរួមអនុវត្តប្រកបដោយមនសិការនិងការភ្ញាក់រឭកទេនោះក៏គ្មានកិច្ចការធំៗណាមួយរបស់ជាតិអាចសម្រេចបានឡើយ ហើយក៏គ្មានសមិទ្ធ-ផលទាំងឡាយអាចកើតឡើង ទៅបានដូចដែលយើងទាំងអស់គ្នាបានឃើញនាពេលសព្វថ្ងៃនេះដែរ ។ ម្យ៉ាងទៀត ការគាំទ្ររបស់ប្រជាជនមកលើគណបក្ស ក៏មិនមែនកើតឡើងដោយចៃដន្យ ដោយគ្មានមូលដ្ឋានច្រាកដប្រជានោះឡើយ ប៉ុន្តែគឺជាការគាំទ្រដោយវិចារណញ្ញាណ ។ ប្រជាជនបានមើលឃើញនូវស្នាដៃធំធេងរបស់គណបក្សក្នុងការបម្រើជាតិ បានមើល ឃើញឆន្ទៈដ៏មោះមុត និងភាពអង់អាចក្លាហានរបស់គណបក្ស ក្នុងការដឹកនាំ និងកែប្រែជោគវាសនាប្រទេសជាតិឲ្យចាកចេញផុតពីឋាននរកនៃសង្គ្រាមរឹតវាអំពើប្រល័យពូជសាសន៍ ការបែកបាក់និរាសព្រាត់ប្រាស់ ក្លាយមកជាទឹកដីនៃសុខសន្តិភាព និងការអភិវឌ្ឍ ។ គណបក្សប្រជាជនកម្ពុជា គឺជាបង្អែកដ៏កក់ក្តៅ ជាក្តីសង្ឃឹមតែមួយគត់របស់ប្រជាជន និងជាគំរូនៃឧត្តមគតិស្នេហាជាតិសម្រាប់យុវជនកម្ពុជាគ្រប់ៗជំនាន់ ។ គុណតម្លៃដ៏ឧត្តុង្គឧត្តមរបស់គណបក្សប្រជាជនកម្ពុជា គឺគ្មានគណ-បក្សនយោបាយណាមួយនៅកម្ពុជា អាចប្រៀបផ្ទឹមបានឡើយ ។ ហេតុនេះ ទើបប្រជាជនកម្ពុជា បន្តផ្តល់ការជឿទុកចិត្ត និងបោះឆ្នោតគាំទ្រគណបក្សប្រជាជនកម្ពុជា ឲ្យទទួលបានជោគជ័យនៅគ្រប់ការបោះឆ្នោត ទាំងការបោះឆ្នោតថ្នាក់ជាតិ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលជាឱកាសដ៏ថ្លៃថ្លា សម្រាប់គណបក្សមានលទ្ធភាពក្នុងការដឹកនាំប្រទេសឲ្យមានការអភិវឌ្ឍដូចសព្វថ្ងៃ ។

Padei Techo Hun Sen, President of the Party and Prime Minister, is the outstanding leader of the Cambodian people and the core of the Cambodian People's Party.

As the ruling party, the Cambodian People's Party upholds responsible role for the fate of the nation and the people before the history. This is a difficult but noble duty, reflecting the fact that the people's trust in the leadership of the party is due to the party has sufficient capacity, human resources, talented leaders and always shares bad and good times with the people no matter how complicated a situation might be. The party has clear policies and leadership paths in all situations. In the Party's politics and activities as a whole, it always adheres to loyalty to the people and takes the people as the goal of its service. In all circumstances, the party always educates officials to do good deeds, connect with the people, listen to their opinions, do nothing to harm the interests of the nation and the people, raise people's awareness, and educate, and inspire the people's movement to participate actively in the implementation of the party's political program to build and defend the motherland.

The party also clearly defined the people as the decisive factor of victory and a solid foundation for supporting the country's leadership. If the people do not understand, do not support and do not participate conscientiously and with awareness in the implementation, no great work of the nation can come to be achievement and no achievements can happen like what everyone sees today. Furthermore, the people's support for the party did not happen by accident without a definite basis. It is intuitive support. The people saw the great achievements of the party in serving the nation, saw the strong will and courage of the party to lead and change the destiny of the nation to leave the hell of war, chaos, genocide, division to become a land of peace and development. The Cambodian People's Party is a warm support, the only hope of the people and a model of patriotic ideals for young Cambodians of all generations. The noble values of the Cambodian People's Party are unmatched by any other political party in Cambodia. That is why the Cambodian people continue to trust and vote for the CPP to succeed in all elections, both national and commune council elections, which is a precious opportunity for the party to be able to lead the country to the development it is today.

The fifth Commune/Sangkat Council election will

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៥ នឹងប្រព្រឹត្តទៅនៅថ្ងៃ ៥ ខែមិថុនា ឆ្នាំ ២០២២ ខាងមុខនេះ ដែលនេះគឺជាពេលវេលាមួយដ៏មានតម្លៃបំផុតសម្រាប់ប្រជាជនកម្ពុជាគ្រប់រូបៗដែលមានសិទ្ធិបោះឆ្នោតត្រូវធ្វើការសម្រេចចិត្ត ពីព្រោះថាការសម្រេចចិត្តមួយដែលត្រឹមត្រូវ នឹងនាំមកនូវការរីកចម្រើនបន្តទៀតរបស់មូលដ្ឋាន ឃុំ-សង្កាត់ និងការលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនឲ្យកាន់តែប្រសើរឡើង ហើយក៏ជាការរួមចំណែកដ៏មានសារៈសំខាន់ក្រៃលែង ដល់ការថែរក្សាឲ្យបានគង់វង្ស សន្តិភាព ស្ថិរភាព និងការអភិវឌ្ឍប្រទេស។ តាមរយៈការបោះឆ្នោតកន្លងមក អាស្រ័យដោយការសម្រេចចិត្តដ៏ត្រឹមត្រូវ ប្រកបដោយសុភវិនិច្ឆ័យរបស់ប្រជាជន ក្នុងការជ្រើសយកគណបក្សប្រជាជនកម្ពុជា ឲ្យដឹកនាំប្រទេស ទាំងនៅថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ទើបយើងបង្កើតបាននូវសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រលើគ្រប់វិស័យ ។ ជាក់ស្តែងនៅក្នុងការដឹកនាំការអនុវត្តគោលនយោបាយអភិវឌ្ឍឃុំ-សង្កាត់ អាណត្តិទី ៤ ឆ្នាំ ២០១៧-២០២២ គណបក្សប្រជាជនកម្ពុជា បានធ្វើឲ្យមានការរីកចម្រើនយ៉ាងខ្លាំង ដោយឃុំ-សង្កាត់នីមួយៗសុទ្ធតែមានការអភិវឌ្ឍមានសុវត្ថិភាពរឹងមាំ ប្រជាជនកាន់តែមានជីវភាពប្រសើរឡើង ហើយបានរស់នៅប្រកបដោយ សុភមង្គល ក្រោមម្លប់នៃសន្តិភាព ។ ដើម្បីពង្រឹង និងពង្រីកសមិទ្ធផលគ្រប់ផ្នែក គ្រប់វិស័យនៅឃុំ-សង្កាត់រយៈពេល ៥ ឆ្នាំបន្តទៀត គណបក្សប្រជាជន កម្ពុជាក៏បានដាក់ចេញនូវគោលនយោបាយអភិវឌ្ឍឃុំ-សង្កាត់ឆ្នាំ ២០២២-២០២៧ ដែលជាការឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជននៅគ្រប់មូលដ្ឋាន។ គោលនយោបាយនេះត្រូវបានកសាងឡើង ដោយឈរ លើមូលដ្ឋានការពិតជាក់ស្តែងនៃការរីកចម្រើនរបស់សង្គមជាតិ ហើយគណបក្ស-ប្រជាជនកម្ពុជា មានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងស្មារតី និងជំហរ ហ៊ានគិត ហ៊ានធ្វើ និងហ៊ានទទួលខុសត្រូវ ដើម្បីសម្រេចឲ្យបានជោគជ័យនូវបំណងប្រាថ្នានេះ ។

គណបក្សគ្រប់ថ្នាក់គ្រប់ផ្នែក ក៏ត្រូវយកចិត្តទុកដាក់ដោះស្រាយឲ្យបានត្រឹមត្រូវ ធានាឲ្យបានជោគជ័យនូវរាល់ភារកិច្ច ដោយខិតខំលើកកម្ពស់សមត្ថភាពដឹកនាំឲ្យឆ្លើយតប នឹងសំណូមពរនៃសភាពការណ៍ និងភារកិច្ច ពង្រឹងសាមគ្គីភាព ឯកភាពផ្ទៃក្នុងរបស់គណបក្សនៅគ្រប់កាលៈទេសៈទាំងខាងទស្សនៈ គោលជំហរសតិអារម្មណ៍ និងសកម្មភាព ដើម្បីធានាជោគជ័យក្នុងការអនុវត្តការប្តេជ្ញាចិត្តជាយុទ្ធសាស្ត្ររបស់ គណបក្សគឺ **"រក្សាប្រៀបឈ្នះក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី ៥ ឆ្នាំ ២០២២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៧ ឆ្នាំ ២០២៣"** ។ ក្នុងស្មារតីនេះ ត្រូវបន្តក្តាប់ជាប់យុទ្ធសាស្ត្រផ្នែកលើអំពើល្អរបស់មន្ត្រីគណបក្ស គុណភាព និងបរិមាណសមាជិកគណបក្ស និងការខិតខំដោះស្រាយតម្រូវការរបស់ប្រជាជននៅមូលដ្ឋានឲ្យបានល្អដើម្បីឈ្នះឆ្នោត ៕

ទស្សនាវដ្តីប្រជាជន

be held on June 5, 2022, which is one of the most valuable times for all eligible Cambodians to make a decision. The right decision will bring about further development of the commune/sangkat community and improve the living standards of the people, and will be an extremely important contribution to the maintenance of lasting peace, stability, and country development. Through past elections, based on the wise and prudent decisions of the people in choosing the CPP to lead the country at both the national and sub-national levels, we have made great historical achievements in all areas. In fact, in leading the implementation of the Commune/Sangkat Development Policy of the fourth term between 2017 and 2022, the Cambodian People's Party has made great progress, with each Commune/Sangkat being in development, in strong security, people's life improvement and people lived happily under the shadow of peace.

To strengthen and expand the achievements in all areas in the communes/sangkats for the next five years, the Cambodian People's Party has also launched the commune/sangkat development policy for 2022-2027 in response to the wishes of the people in every locality. Built on the basis of the realities of the progress of the society, this policy and the CPP has the capability and ability in spirit and position, daring to think, daring to do and daring to take responsibility, to achieve the aspired goals.

Parties at all levels must take care to properly address all tasks by striving to enhance their leadership to respond to the demands of the situation and the task of strengthening the party's internal unity in all circumstances – in view, position, spirit, and actions. This is to ensure the success of the implementation of the party's strategic commitment to "maintain the winning advantages in the fifth Commune/Sangkat Council Election in 2022 and the 7th National Assembly Election 2023." In this sense, we must continue to adhere to the strategy based on the good deeds of party officials, the quality and quantity of party members, and the efforts to address the needs of the local people well in order to win the election./.

THE PRACHEACHUN MAGAZINE

គណបក្សប្រជាជនកម្ពុជា រួមសុខ រួមទុក្ខជាមួយប្រជាជននៅគ្រប់កាលៈទេសៈ

សាលក្រមផ្តន្ទាទោសមេក្លោង និងបក្សពួកប៉ុនប៉ងធ្វើរដ្ឋប្រហារ គឺជាការផ្តល់យុត្តិធម៌ជល់ប្រជាជនកម្ពុជា

កាលពីថ្ងៃទី១៧ ខែមីនា សាលាដំបូងរាជធានីភ្នំពេញ បានប្រកាសសាលក្រមផ្តន្ទាទោសមេឧទ្ទាមក្រៅច្បាប់ ឈ្មោះ សម រង្សី និងមេក្លោងចំនួន ៦រូបទៀតដែលបានរៀបចំផែនការធ្វើរដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាល ឲ្យជាប់ពន្ធនាគារក្នុងម្នាក់ៗចំនួន ១០ឆ្នាំ ព្រមទាំងបានផ្តន្ទាទោសជនរួមគំនិត ១៤នាក់ទៀត ឲ្យជាប់ពន្ធនាគារ ៥ឆ្នាំ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យព្យួរទោស ។ សាលក្រមនេះបានផ្តល់យុត្តិធម៌យ៉ាងត្រឹមត្រូវជូនប្រជាជនកម្ពុជា ដែលជាម្ចាស់ឆ្នោត និងរាជរដ្ឋាភិបាលកម្ពុជាដែលបានកើតចេញពីឆន្ទៈរបស់ប្រជាជនតាមរយៈការបោះឆ្នោត ព្រមទាំងជួយពង្រឹងថែមទៀតដល់ការអនុវត្តគោលការណ៍នីតិរដ្ឋ និងដំណើរការពូនជ្រុំលទ្ធិប្រជាធិបតេយ្យ នៅប្រទេសកម្ពុជាឲ្យកាន់តែមានជំហានរីកលូតលាស់ឡើង ។ នៅពេលដែលប្រជាជនកម្ពុជាទូទាំងប្រទេសទទួលបានយុត្តិធម៌ ប៉ុន្តែសកម្មជនសិទ្ធិមនុស្សមួយចំនួន ដែលក្នុងនោះរួមមានទាំងអង្គការសិទ្ធិមនុស្ស Human Rights Watch បែរជាប្រតិកម្មទាំងទទឹងទិស ដោយចោទប្រកាន់ថា សាលក្រមនេះគ្មានភាពត្រឹមត្រូវ ជាសវនាការដែលធ្វើឡើងក្នុងបំណងកំចាត់គូបដិបក្សនយោបាយទៅវិញ ។ តាមពិត គឺពួកធ្វើការងារសិទ្ធិមនុស្សទាំងនោះទៅវិញទេ ដែលមានចេតនាក្នុងការបង្វែរបញ្ហាផ្លូវច្បាប់ឲ្យទៅជារឿងនយោបាយ ។ ពួកគេនិយាយតែពីសិទ្ធិមនុស្ស និយាយពីប្រជាធិបតេយ្យ ប៉ុន្តែពួកគេមិនដែលចាប់អារម្មណ៍ទៅលើគោលការណ៍នីតិរដ្ឋទាល់តែសោះ ។

យើងគប្បីរំឲ្យកឲ្យយើញអំពីអង្គហេតុ និងអង្គច្បាប់នៃបញ្ហានេះ ដើម្បីឲ្យមនុស្សមួយចំនួន ពិសេសពួកសិទ្ធិមនុស្សមួយក្រុមដែលតែងតែវាយប្រហារមកលើស្ថាប័នតុលាការ ដើម្បីយកធ្វើជាមូលដ្ឋានសម្រាប់ការពិចារណា និងធ្វើការវិនិច្ឆ័យឲ្យបានត្រឹមត្រូវច្បាស់លាស់ ។ ហេតុការណ៍បានចាប់ផ្តើមឡើង កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៩ គឺទណ្ឌិត សម រង្សី បានធ្វើការអំពាវនាវឲ្យប្រជាជនកម្ពុជាប្រើប្រាស់ **«អំណាចប្រជាជន»** ក្នុងការចូលរួមទទួលដំណើរមាតុភូមិនិវត្តន៍របស់ខ្លួន នៅថ្ងៃទី៩ វិច្ឆិកា ឆ្នាំ២០១៩ ។ ទណ្ឌិតរូបនេះបានប្រកាសចេញគោលនយោបាយមួយចំនួន ដែលមានចរឹតជារដ្ឋប្រហារពេញលក្ខណៈនោះគឺ ការអំពាវនាវឲ្យកងទ័ពជាតិផ្តាច់ខ្លួន ហើយកាន់អាវុធប្រឆាំងរាជរដ្ឋាភិបាល ការប្រកាសបង្កើតមូលនិធិសម្រាប់ទ្រទ្រង់កងទ័ពខុសច្បាប់ ញុះញង់ប្រជាជនឲ្យក្រោកឈរធ្វើការបះបោរប្រឆាំងរាជរដ្ឋាភិបាល ការប្រើប្រាស់រៀហាសាស្ត្រវាយប្រហារប្រមាថមាក់ងាយមកលើអង្គព្រះមហាក្សត្រជាទីគោរពសក្ការៈរបស់ប្រជាជន ។ ផែនការទាំងអស់នេះ មានលក្ខណៈជាឧទ្ទាមកម្ម ដែលនឹងនាំទៅដល់ការបំផ្លាញសុខសន្តិភាព ការបំបែកបំបាក់ជាតិ ដែលអាចបង្ក ឲ្យមានគ្រោះមហន្តរាយធ្ងន់ធ្ងរមិនអាចប៉ាន់ស្មានបានចំពោះជាតិ និងប្រជាជនកម្ពុជា ។ ផែនការរបស់ទណ្ឌិត សម រង្សី មានទម្រង់ជាការញុះញង់ បំផុសប្រមូលប្រជាជន និងកងកម្លាំងប្រដាប់អាវុធដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោត គឺជាសកម្មភាពខុសច្បាប់ និងប៉ះពាល់ដល់សន្តិសុខជាតិ ជាឧក្រិដ្ឋកម្មដែលត្រូវតែផ្តន្ទាទោសឲ្យធ្ងន់ធ្ងរជាទីបំផុត ទោះផែនការនេះធ្វើឡើងក្នុងទម្រង់ជារដ្ឋប្រហារក្តី ជាកុប្បកម្មក្តី ជាបដិវត្តន៍ដោយហឹង្សាក្តី ឬដោយការប្រើអំណាចប្រជាជនតាមរយៈបដិវត្តន៍ពណ៍ក្តី ។ ការដណ្តើមអំណាច ទោះតាមវិធីណាក៏ដោយក្រៅពីតាមរយៈការបោះឆ្នោត តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជាអំពើខុសច្បាប់ដែលសមត្ថកិច្ចត្រូវចាត់គ្រប់វិធានការដើម្បីបង្ការ ទប់ស្កាត់ឲ្យខាងតែបាន ។ អ្នកធ្វើការងារសិទ្ធិមនុស្សទាំងឡាយត្រូវតែយល់ឲ្យច្បាស់ថា ការចាត់វិធានការច្បាប់ចំពោះទង្វើរទាំងឡាយណាដែលប៉ុនប៉ងបំផ្លាញសុខសន្តិភាព ស្ថិរភាពនយោបាយ ការញុះញង់ឲ្យមានអំពើហឹង្សា ចលនាបំបែកបំបាក់ផ្ទៃក្នុងជាតិ ឈានទៅផ្តួលរំលំរាជរដ្ឋាភិបាល ពុំមែនជាសកម្មភាពរំលោភសិទ្ធិមនុស្ស ក្នុងសង្គមប្រជាធិបតេយ្យនោះទេ ប៉ុន្តែនេះជាការការពារនីតិរដ្ឋ និងប្រជាធិបតេយ្យ ។

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសថា ផែនការប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ក្រុមឧទ្ទាមដឹកនាំដោយទណ្ឌិត សម រង្សី បានទទួលបរាជ័យទាំងស្រុង ហើយសន្តិសុខសណ្តាប់ធ្នាប់សាធារណៈត្រូវបានធានាយ៉ាងរឹងមាំក្នុងក្របខណ្ឌទូទាំងប្រទេស ។ ប្រជាជនកម្ពុជាបានបង្ហាញនូវធ្លុងសាមគ្គីភាព ឯកភាពជាតិយ៉ាងរឹងមាំជាមួយរាជរដ្ឋាភិបាល ក្នុងការការពារថែរក្សាសុខសន្តិភាព និងស្ថិរភាពសង្គម ជាពិសេសបានបង្ហាញនូវស្វាមីភក្តិចំពោះអង្គព្រះមហាក្សត្រជាទីគោរពសក្ការៈខ្ពង់ខ្ពស់បំផុត ។ តាមរយៈជោគជ័យនេះ បានធ្វើឲ្យសន្តិភាព ស្ថិរភាព សន្តិសុខ ការអភិវឌ្ឍ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា កាន់តែត្រូវបានពង្រឹងយ៉ាងរឹងមាំ ។ ប្រជាជនកាន់តែមានការជឿជាក់លើការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ។

សំណុំរឿងនៃផែនការ ប៉ុនប៉ងធ្វើរដ្ឋប្រហាររបស់ទណ្ឌិតក្បត់ជាតិ សម រង្សី និងបក្សពួក ក៏ត្រូវបានតុលាការចាត់វិធានការតាមផ្លូវច្បាប់ ។ យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ផែនការសកម្មភាពរបស់ទណ្ឌិត សម រង្សី ត្រូវបានកំណត់ជាអំពើប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ ដែលត្រូវផ្តន្ទាទោស ៖ ទី១-ផែនការប៉ុនប៉ងធ្វើរដ្ឋប្រហារ ដើម្បីផ្តួលរំលំរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺជាបទឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលត្រូវផ្តន្ទាទោសក្រោម «បទល្មើសឧបយាត» ជាសកម្មភាពដោយហិង្សាជារដ្ឋប្រហារផ្តួលរំលំរាជរដ្ឋាភិបាល ផ្អែកតាមបញ្ញត្តិមាត្រា៤៥១ និងមាត្រា៤៥២ នៃក្រមព្រហ្មទណ្ឌ ដែលនឹងត្រូវប្រឈមការទទួលដោយទោសដាក់ពន្ធនាគារពី ១៥ ទៅ ៣០ឆ្នាំ ហើយប្រសិនបើជនល្មើសជាអ្នករាយការណ៍សាធារណៈ ទោសសម្រាប់ «បទល្មើសឧបយាត» នេះត្រូវដាក់ពន្ធនាគារអស់មួយជីវិត **ទី២**-ចំពោះរាល់បុគ្គលទាំងឡាយដែលគាំទ្រ ឬចូលរួមនៅក្នុងគម្រោងនេះ ក៏ត្រូវដាប់ទោសពី «បទល្មើសរួមគំនិតក្បត់» ដែលជាបទឧក្រិដ្ឋមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤៥៣ នៃក្រមព្រហ្មទណ្ឌ ដែលនឹងត្រូវប្រឈមការទទួលទោសពន្ធនាគារពី ៥ ទៅ ១០ឆ្នាំ ហើយទោសនេះត្រូវបន្ថែមទម្ងន់ដាក់ពន្ធនាគារពី ១០ ទៅ ២០ឆ្នាំ ប្រសិនបើជនល្មើស គឺជាអ្នករាយការណ៍សាធារណៈ ។ ដោយឡែកចំពោះបុគ្គលណា ដែលបានចូលរួមក្នុងអំពើរួមគំនិតក្បត់ខាងលើ ហើយបុគ្គលនោះបានសារភាពចំពោះមុខអាជ្ញាធរមានសមត្ថកិច្ច និងសហការបង្ក្រាបបទល្មើសនេះ នឹងត្រូវទទួលបានការលើកលែងឲ្យរួចផុតពីការទទួលទោស ដោយអនុលោមតាមបញ្ញត្តិមាត្រា៤៥៤ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ទី៣-ការប្រើរចនាសម្ព័ន្ធនៃអតីតគណបក្សសង្គ្រោះជាតិគ្រប់លំដាប់ថ្នាក់ ដែលគណបក្សនេះត្រូវបានតុលាការកំពូលសម្រេចរំលាយចោល ដើម្បីចូលរួមអនុវត្តផែនការខាងលើ គឺជាទង្វើប្រឆាំងនឹងសាលដីការបស់តុលាការកំពូលផង ខុសទៅនឹងច្បាប់ស្តីពីគណបក្សនយោបាយផង និងខុសទៅនឹងច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

ទោះបីជាស្ថិតនៅក្នុងមជ្ឈដ្ឋានណា ឬមាននិន្នាការអ្វីក៏ដោយ ពួកគេត្រូវតែគាំទ្រសច្ចធម៌ និងផ្តល់យុត្តិធម៌ ដោយមិនលំអៀង ធ្វើយ៉ាងណាជួយពង្រឹងដំណើរការ គោលការណ៍នីតិរដ្ឋ និងការអនុវត្តលទ្ធិប្រជាធិបតេយ្យឲ្យបោះជំហានទៅមុខទៀត ប្រកបដោយភាពរឹងមាំ ។

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ៖ ចំណាក់ចំនងកម្ពុជា-ឡាវ ត្រូវបានលើកកម្ពស់ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង

*សម្តេចភក្តី **សាយ ឈុំ** អនុញ្ញាតឱ្យឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃព្រះរាជាណាចក្រឡាវ ដែលទើបតែងតាំងថ្មីប្រចាំកម្ពុជា ចូលជួបជូនសារតាំង*

នាព្រឹកថ្ងៃទី១៥ខែមីនា ឆ្នាំ២០២២ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រមុខរដ្ឋស្តីទី ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** (Buakeo PHUMVONGSAY) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដែលទើបតែងតាំងថ្មីប្រចាំកម្ពុជា ចូលជួបជូនសារតាំងនៅវិមានព្រឹទ្ធសភា។ ក្នុងព្រះបរមនាម **ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងនាមព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមសម្តេចផ្ទាល់ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** បានសម្តែងនូវការស្វាគមន៍ដ៏កក់ក្តៅចំពោះ ឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** ដែលត្រូវបានប្រធានរដ្ឋឡាវ តែងតាំងជាឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពឡាវប្រចាំកម្ពុជា។

ក្នុងឱកាសនោះ **សម្តេចវិបុលសេនាភក្តី សាយ ឈុំ** បានសម្តែងក្តីសោមនស្សរីករាយ និងពេញចិត្តជាខ្លាំង ដោយបានមើលឃើញចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការរវាងប្រជាជននៃប្រទេសទាំងពីរ មានការរីកចម្រើនជាបន្តបន្ទាប់ឥតឈប់ឈរលើគ្រប់វិស័យ ។ ទំនាក់ទំនងនេះ ត្រូវបានលើកកម្ពស់ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង។ សម្តេចវិបុលសេនាភក្តីប្រមុខរដ្ឋស្តីទី មានជំនឿជឿជាក់ថា ក្នុងហ៊ាន:ជាឯកអគ្គរដ្ឋទូតឡាវប្រចាំកម្ពុជា ឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** នឹងខិតខំពង្រឹងពង្រីកនូវចំណងមិត្តភាព សាមគ្គីភាព និងកិច្ចសហប្រតិបត្តិការឱ្យកាន់តែរឹងមាំ ស៊ីជម្រៅបន្ថែមទៀតលើបញ្ហានយោបាយ សន្តិសុខ ការពារជាតិ អប់រំ សុខាភិបាល និងខិតខំជំរុញឱ្យមានការផ្លាស់ប្តូរពាណិជ្ជកម្ម សេដ្ឋកិច្ចវិនិយោគ ទេសចរណ៍ វប្បធម៌ និងការផ្លាស់ប្តូររវាងប្រជាជន និងប្រជាជនឱ្យកាន់តែទូលំទូលាយ ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រទេស និងប្រជាជនទាំងពីរ។ សម្តេចវិបុលសេនាភក្តី បានបញ្ជាក់ថា ព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល ក្រសួងស្ថាប័នជាតិនៃកម្ពុជា ត្រៀមខ្លួនជានិច្ចដើម្បីធ្វើកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយឯកឧត្តមឯកអគ្គរដ្ឋទូត ក៏ដូចជាស្ថានទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ប្រចាំកម្ពុជា ដើម្បីនាំមកនូវផលប្រយោជន៍សម្រាប់ប្រជាជន នៃប្រទេសទាំងពីរ ទៅវិញទៅមក។

សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទី ក៏បានធ្លាំធ្លើនូវព្រះរាជបណ្តាំសួរសុខទុក្ខដោយសេចក្តីគោរព និងសេចក្តីនឹករលឹកពី**ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** និងថ្នាក់ដឹកនាំកំពូលជាតិនៃកម្ពុជាជូនចំពោះប្រធានរដ្ឋ និងថ្នាក់ដឹកនាំជាន់ខ្ពស់គ្រប់លំដាប់ថ្នាក់នៃសាធារណរដ្ឋ ប្រជាធិបតេយ្យប្រជាមានិតឡាវ។ សម្តេចប្រមុខរដ្ឋស្តីទី បានប្រសិទ្ធពរជូនឯកអគ្គរដ្ឋទូតឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** សូមមានសុខភាពល្អ និងទទួលបានជោគជ័យ ក្នុងបេសកកម្មការទូតដ៏ឧត្តុង្គឧត្តម។

នៅក្នុងឱកាសនោះ ឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសម្តេចប្រមុខរដ្ឋស្តីទី ដែលបានចំណាយពេលវេលាដ៏មានតម្លៃអនុញ្ញាតឱ្យរូបឯកឧត្តម បានចូលជូនសារតាំងនិងសម្តែងការគួរសមនិងបានពាំនាំនូវការសួរសុខទុក្ខពីសំណាក់ប្រធានរដ្ឋ និងថ្នាក់ដឹកនាំកំពូលឡាវ ថ្វាយ**ព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចកកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ និងជូនចំពោះ សម្តេចប្រមុខរដ្ឋស្តីទី និងថ្នាក់ដឹកនាំកំពូលកម្ពុជា។ ឯកឧត្តម **ប៊ូរកែវ ភូមិវង្សៃ** បានសម្តែងនូវសេចក្តីរីករាយចំពោះទំនាក់ទំនងសាមគ្គីភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងរដ្ឋាភិបាល និងប្រជាជននៃប្រទេសទាំងពីរ និងបានវាយតម្លៃខ្ពស់ចំពោះវឌ្ឍនភាព និងការរីកចម្រើនរបស់កម្ពុជា។ ឯកឧត្តមក៏បានថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដែលបានជួយឧបត្ថម្ភគាំទ្រដល់ប្រទេសឡាវ នាពេលកន្លងទៅ ជាពិសេសការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ វ៉ាក់សាំង រថយន្តដឹកវ៉ាក់សាំង និង ឧបករណ៍វេជ្ជសាស្ត្រមួយចំនួន។ ប្រទេសឡាវ សូមគាំទ្រចំពោះតួនាទី របស់ប្រទេសកម្ពុជាជាប្រធានអាស៊ានផងដែរ ៕

ចំណងចំណងនៃប្រទេសជាំងពីរកម្ពុជា-ជប៉ុន ស្ថិតក្នុងកម្រិតល្អបំផុតដែលពុំធ្លាប់មាន



សម្តេចតេជោ ហ៊ុន សែន *នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញទទួលស្វាគមន៍ជាផ្លូវការ ដំណើរបំពេញទស្សនកិច្ចរបស់ឯកឧត្តម* ***គីស៊ីដា ហ្វូមីអូ*** *នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន*

តបតាមការអញ្ជើញរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ឯកឧត្តម **គីស៊ីដា ហ្វូមីអូ** (KISHIDA Fumio) នាយករដ្ឋមន្ត្រីនៃប្រទេសជប៉ុន បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការ នៅព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២។

ក្នុងឱកាសជួបពិភាក្សាការងារ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និងឯកឧត្តមនាយករដ្ឋមន្ត្រី **គីស៊ីដា** បានទទួលស្គាល់ថា ទំនាក់ទំនងនៃប្រទេសទាំងពីរ គឺស្ថិតក្នុងកម្រិតល្អបំផុតដែលពុំធ្លាប់មាន។ នាយករដ្ឋមន្ត្រីទាំងពីរ បានចែករំលែកនូវទស្សនៈនៅលើបញ្ហាសំខាន់ៗមួយចំនួន។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងអំណរគុណចំពោះកិច្ចសហប្រតិបត្តិការដ៏ទូលំទូលាយរបស់ជប៉ុនរួមមាន ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច និងសង្គម ការអភិវឌ្ឍធនធានមនុស្ស និងការគាំទ្រនៅថ្នាក់មូលដ្ឋាន។ សម្តេចតេជោបានវាយតម្លៃខ្ពស់ចំពោះការគាំទ្ររបស់ជប៉ុន ជាពិសេសការកសាងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅកម្ពុជា រួមមានកំពង់ផែសមុទ្រ ស្ពាន ផ្លូវថ្នល់ ការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត។ នាយករដ្ឋមន្ត្រីទាំងពីរ បានឯកភាពគ្នាសហការយ៉ាងពេញទំហឹង ដើម្បីធ្វើឲ្យកំពង់ផែក្រុងព្រះសីហនុ ក្លាយជាកំពង់ផែដ៏សំខាន់ចម្បងមួយ ដែលមិនមែនសម្រាប់តែកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់តំបន់មេគង្គ និងពិភពលោកផងដែរ។ ក្នុងឱកាសខួប អនុស្សាវរីយ៍លើកទី៣០ នៃការចូលរួមរបស់កងកម្លាំងស្ម័យការពារជប៉ុន ក្នុងប្រតិបត្តិការរក្សាសន្តិភាព (PKO) នៅកម្ពុជា ឯកឧត្តមនាយករដ្ឋមន្ត្រី **គីស៊ីដា** បានវាយតម្លៃខ្ពស់ចំពោះការពិតដែលកម្ពុជាបានផ្លាស់ប្តូរពីប្រទេសដែលទទួលយកប្រតិបត្តិការរក្សាសន្តិភាព ទៅជាប្រទេសដែលបញ្ជូនកងទ័ពចូលរួមប្រតិបត្តិការ រក្សាសន្តិភាព និងចូលរួមជាមួយសហគមន៍អន្តរជាតិ ដើម្បីបុព្វហេតុសន្តិភាពនិងស្ថិរភាពអន្តរជាតិ។ ឯកឧត្តម **គីស៊ីដា** បានកត់សម្គាល់ថា «រាល់ពេលនៃទស្សនកិច្ចនៅកម្ពុជា ខ្ញុំគិតទៅដល់តម្លៃសន្តិភាព។ ខ្ញុំសូមសម្តែងនូវការគោរពជូនដល់ប្រជាជនកម្ពុជា ចំពោះស្មារតីដែលមិនបោះបង់ រហូតទាល់តែកសាងប្រទេសឡើងវិញ បានពីការបំផ្លិចបំផ្លាញដែលបណ្តាលមកពីសង្គ្រាមស៊ីវិល ។ យើងគួររៀនពីស្មារតីកម្ពុជា ដោយសារនៅលើពិភពលោកនាពេលបច្ចុប្បន្នកំពុងមានការគំរាមដល់ជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសន្តិភាព»។

នាយករដ្ឋមន្ត្រីទាំងពីរ បានស្វាគមន៍ចំពោះដំណើរបំពេញទស្សនកិច្ចផ្លូវការ ប្រកបដោយជោគជ័យរបស់ ឯកឧត្តមឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយុទ្ធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោកភូមិន្ទ នៅប្រទេសជប៉ុន កាលពីខែមុន។ នាយករដ្ឋមន្ត្រីទាំងពីរ បានស្វាគមន៍ការចូលចតរបស់នាវាកងកម្លាំងស្ម័យការពារជើងទឹក នៅកំពង់ផែក្រុងព្រះសីហនុនិងការធ្វើសមយុទ្ធសុឆ្ពន្ធៈ ក៏ដូចជាដំណើរទស្សនកិច្ចទៅកាន់មូលដ្ឋានកងទ័ពជើងទឹករបស់កងកម្លាំងស្ម័យការពារជើងទឹក។ នាយករដ្ឋមន្ត្រីទាំងពីរក៏បានយល់ព្រមសម្របសម្រួលសកម្មភាពនានា សម្រាប់ការថែរក្សាសន្តិភាព តាមរយៈការកសាងសមត្ថភាព លើវិស័យប្រតិបត្តិការរក្សាសន្តិភាព និងកិច្ចសហប្រតិបត្តិការ ក្នុងការចែករំលែកបទពិសោធន៍របស់កម្ពុជាផ្នែកបោសសម្អាតមីនជាមួយប្រទេសទីបី។

សម្តេចតេជោ ហ៊ុន សែន បានកោតសរសើរយ៉ាងខ្លាំងចំពោះការវិនិយោគរបស់ក្រុមហ៊ុនជប៉ុន ដែលបានរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ការធ្វើពិពិធកម្មឧស្សាហកម្មរបស់កម្ពុជា។ ឯកឧត្តមនាយករដ្ឋមន្ត្រី **គីស៊ីដា** បានស្វាគមន៍ចំពោះការអនុវត្តច្បាប់វិនិយោគថ្មីរបស់កម្ពុជា ដែលជំរុញការពង្រីកអាជីវកម្ម កាលពីខែតុលា ឆ្នាំ២០២១។ ដើម្បីជំរុញការវិនិយោគរបស់ក្រុមហ៊ុនជប៉ុន នាយករដ្ឋមន្ត្រីទាំងពីរបានឯកភាពគ្នាលើកកម្ពស់បន្ថែមទៀតនូវបរិយាកាសវិនិយោគរបស់កម្ពុជា ដោយរដ្ឋមន្ត្រីពាក់ព័ន្ធ តាមរយៈកិច្ចព្រមព្រៀងវិនិយោគទ្វេភាគី និងកិច្ចប្រជុំវិស័យសាធារណៈ និងឯកជន។

នាយករដ្ឋមន្ត្រីទាំងពីរ បានបញ្ជាក់ពីគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការ លើវិស័យសន្តិសុខសេដ្ឋកិច្ច ដែលជាវិស័យថ្មីមួយនៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងជប៉ុន។ នាយករដ្ឋមន្ត្រីទាំងពីរ បានសម្តែងការព្រួយបារម្ភអំពីការបង្កឹតបង្កំផ្នែកសេដ្ឋកិច្ច និងសង្កត់ធ្ងន់អំពីសារសំខាន់នៃការពង្រឹងសណ្តាប់ធ្នាប់សេដ្ឋកិច្ចអន្តរជាតិ ដើម្បីទប់ទល់

នឹងបញ្ហាប្រឈមថ្មីៗដូចជាការបង្កិតបង្កំផ្នែកសេដ្ឋកិច្ចជាដើម។ នាយករដ្ឋមន្ត្រីទាំងពីរ បានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាចិត្តរួមគ្នាក្នុងក្របខណ្ឌអង្គការសហប្រជាជាតិ ចំពោះតរិយាបថរបស់រដ្ឋដែលមានការទទួលខុសត្រូវចំពោះប្រព័ន្ធCyber (សន្តិសុខបណ្តាញគមនាគមន៍) ក្នុងនោះរួមមាន ការអនុវត្តច្បាប់អន្តរជាតិ ការគាំទ្រការអនុវត្តវិធានការដោយស្ម័គ្រចិត្ត ជាមួយនឹងបទដ្ឋានមិនជាប់កាតព្វកិច្ច និងការកសាងទំនុកចិត្ត ក៏ដូចជាការគាំទ្រការកសាងសមត្ថភាព Cyber ។

ឯកឧត្តមនាយករដ្ឋមន្ត្រី **គីស៊ីដា** បានជម្រាបជូន **សម្តេចតេជោ ហ៊ុន សែន** អំពីគោលបំណង ផ្តល់កិច្ចសហប្រតិបត្តិការ ដើម្បីភាពជោគជ័យនៃព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ (SEA Games) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះជាលើកដំបូង នៅឆ្នាំ២០២៣ តាមរយៈការជួយជំរុញប្រជាប្រិយភាពនៃវិស័យអប់រំកាយនៅកម្ពុជា និងការចែករំលែកបទពិសោធន៍នៃការធ្វើជាម្ចាស់ផ្ទះកីឡាអូឡាំពិក និងប៉ារ៉ាឡាំពិកទីក្រុងតូក្យូឆ្នាំ២០២០។ នាយករដ្ឋមន្ត្រីទាំងពីរបានរំឭកថាខែតុលាឆ្នាំ២០២១ ជាខួបលើកទី៣០ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីកម្ពុជា ហើយបានកោតសរសើរថា កម្ពុជាសម្រេចបាននូវការអភិវឌ្ឍនាពេលបច្ចុប្បន្នដោយការខិតខំប្រឹងប្រែងដ៏ធំធេងរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ដោយមានកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ រួមទាំងប្រទេសជប៉ុនផងដែរ។ នាយករដ្ឋមន្ត្រីទាំងពីរ បានវាយតម្លៃខ្ពស់ចំពោះការផ្លាស់ប្តូរទស្សនៈគ្នាត្រង់ទៅត្រង់មកវាងប្រទេសទាំងពីរលើបញ្ហាសិទ្ធិមនុស្ស លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ដោយផ្អែកលើការជឿទុកចិត្តគ្នាទៅវិញទៅមក។ ឯកឧត្តមនាយករដ្ឋមន្ត្រី **គីស៊ីដា** បានបង្ហាញចេតនាគាំទ្រដល់ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋ ដូចជាការរៀបចំការបោះឆ្នោតតាមវិធីមួយ ដែលឆ្លុះបញ្ចាំងពីសំឡេងចម្រុះពីប្រជាជនកម្ពុជាតាមរយៈគម្រោងនានារួមមានការលើកកម្ពស់កិច្ចសន្ទនារវាងរដ្ឋាភិបាលកម្ពុជា និងសង្គមស៊ីវិល ការពង្រឹងអភិបាលកិច្ចតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋនិងជំនួយបច្ចេកទេសផ្នែកច្បាប់។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានកោតសរសើរ ចំពោះការគាំទ្ររបស់ប្រទេសជប៉ុនក្នុងវិស័យនេះ ហើយបានបង្ហាញពីបំណងរបស់សម្តេច ក្នុងការខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបញ្ចូលលទ្ធផលនៃការគាំទ្រទាំងនោះទៅក្នុងសង្គមកម្ពុជា។

ទាក់ទិនទៅនឹងវិបត្តិរុស្ស៊ី-អ៊ុយក្រែននាយករដ្ឋមន្ត្រីទាំងពីរបានរំឭកថាប្រទេសទាំងពីរបានចូលរួមជាមួយប្រទេសសហស្ថាបនិកនៃសេចក្តីសម្រេចចិត្តលេខ A/RES/ES-11/1N ដែលត្រូវបានអនុម័តនៅក្នុងសម័យប្រជុំពិសេសបន្ទាន់លើកទី១១ នៃមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី២ ខែមីនា និងថារដ្ឋមន្ត្រីការបរទេសអាស៊ានបានចេញសេចក្តីថ្លែងការណ៍ស្តីពីអ៊ុយក្រែននៅថ្ងៃទី២៦ ខែកុម្ភៈ និងទី៣ ខែមីនា ឆ្នាំ២០២២។ ថ្នាក់ដឹកនាំទាំងពីរ បានចែករំលែកទស្សនៈថា ការឈ្លានពានទៅលើរដ្ឋសមាជិកអង្គការសហប្រជាជាតិមួយ ដោយបំពានលើអធិបតេយ្យភាព និងបូរណភាពទឹកដីរបស់រដ្ឋនោះ គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរ លើច្បាប់អន្តរជាតិដែលហាមប្រើប្រាស់កម្លាំង និងជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើធម្មនុញ្ញអង្គការសហប្រជាជាតិ ។ ក្នុងស្មារតីនេះ នាយករដ្ឋមន្ត្រីទាំងពីរ បានបញ្ជាក់ពីការប្តេជ្ញាចិត្តក្នុងការរក្សាសន្តិភាព ស្ថិរភាព និងសន្តិសុខ នៅឥណ្ឌូ-ប៉ាស៊ីហ្វិក។ សម្តេចតេជោ បានសង្កត់ធ្ងន់ពីបទពិសោធន៍ផ្ទាល់ខ្លួនថា សង្គ្រាមមិនអាចបញ្ចប់សង្គ្រាមបាននោះទេ ហើយគួរតែបន្តស្វែងរកដំណោះស្រាយដោយសន្តិវិធី។ នាយករដ្ឋមន្ត្រីទាំងពីរ បានទទូចឱ្យមានការបញ្ឈប់ការប្រើកម្លាំងជាបន្ទាន់ និងដកកម្លាំងយោធាចេញពីទឹកដីអ៊ុយក្រែន។

នាយករដ្ឋមន្ត្រីទាំងពីរ បានទទួលស្គាល់ថា ស្ថានការណ៍នៅអ៊ុយក្រែនបានបង្ហាញថា ការសម្រេចបាននូវកំណែទម្រង់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យបានឆាប់ជាកិច្ចការចាំបាច់ដើម្បីដោះស្រាយបញ្ហាធ្ងន់ធ្ងរ ដែលសហគមន៍អន្តរជាតិកំពុងប្រឈមមុខ ហើយថ្នាក់ដឹកនាំទាំងពីរ បានបញ្ជាក់សាជាថ្មីពីការបន្តកិច្ចសហប្រតិបត្តិការដើម្បីសម្រេចបាននូវកំណែទម្រង់នេះ។ ឯកឧត្តមនាយករដ្ឋមន្ត្រី គីស៊ីដា បានថ្លែងអំណរគុណកម្ពុជា ចំពោះការគាំទ្រមិនផ្លាស់ប្តូរចំពោះកំណែទម្រង់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ រួមទាំងការគាំទ្រប្រទេសជប៉ុនដើម្បីក្លាយជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សានេះ។

នាយករដ្ឋមន្ត្រីទាំងពីរ បានសម្តែងការព្រួយបារម្ភចំពោះស្ថានភាពនៅក្នុងប្រទេសមីយ៉ាន់ម៉ា និងអំពាវនាវឱ្យបញ្ឈប់ជាបន្ទាន់នូវអំពើហិង្សា បញ្ឈប់ការនាំអាវុធចូល និងស្តើគ្រប់ភាគីទាំងអស់ឱ្យធ្វើការអត់ធ្មត់ជាអតិបរមា និងចាប់ផ្តើមដំណើរការចរចា សម្រាប់ដំណោះស្រាយប្រកបដោយសន្តិវិធីដោះលែងអ្នកជាប់ឃុំដោយរឿងនយោបាយក៏ដូចជាការវិលត្រឡប់ទៅរកប្រក្រតីភាព និងប្រព័ន្ធនយោបាយប្រជាធិបតេយ្យ។ នាយករដ្ឋមន្ត្រីទាំងពីរ បានឯកភាពគ្នាទាមទារឱ្យមានការជំរុញសកម្មភាពជាក់ស្តែងនានា ដើម្បីអនុវត្ត **"ការព្រមព្រៀងជាឯកច្ឆន្ទ ៥ចំណុច"** ដែលសម្រេចបាននៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំអាស៊ាន នៅថ្ងៃទី២៤ មេសា ២០២១ ឱ្យបានឆាប់រហ័ស។ នាយករដ្ឋមន្ត្រីទាំងពីរ បានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបន្តសាកល្បងមីស៊ីលបាលីស្ទីកដោយសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ (ស.ប.ប.កូរ៉េ) ដែលបង្កើនភាពតានតឹង និងឥទ្ធិពលជាអវិជ្ជមានដល់បរិយាកាសនៃកិច្ចចរចាដើម្បីដោះស្រាយការគំរាមកំហែងដល់សន្តិភាព និងសន្តិសុខក្នុងតំបន់និងអន្តរជាតិ។ នាយករដ្ឋមន្ត្រីទាំងពីរ បានអះអាងសាជាថ្មីអំពីសារសំខាន់នៃការរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព នៃការធ្វើនាវាចរណ៍ និងការហោះហើរពីលើសមុទ្រចិនខាងត្បូង ការអត់ធ្មត់រៀងៗខ្លួន ភាពគ្មានយោធូបនីយកម្ម និងការដោះស្រាយជម្លោះដោយសន្តិវិធី ដោយអនុលោមតាមច្បាប់អន្តរជាតិ រួមទាំងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រឆ្នាំ ១៩៨២ (UNCLOS) ។ នាយករដ្ឋមន្ត្រីទាំងពីរ បានគូសបញ្ជាក់ពីសារសំខាន់នៃការជំរុញឱ្យប្រទេសពាក់ព័ន្ធជៀសវាងសកម្មភាពឯកតោភាគីដែលនឹងបង្កើនភាពតានតឹង ឬធ្វើឱ្យស្ថានការណ៍មានភាពស្មុគស្មាញនៅសមុទ្រចិនខាងត្បូង ។ នាយករដ្ឋមន្ត្រីទាំងពីរ បានសង្កត់ធ្ងន់ពីសារសំខាន់នៃការអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវសេចក្តីថ្លែងការណ៍ស្តីពីការប្រតិបត្តិរបស់ភាគីនៅសមុទ្រចិនខាងត្បូង (DOC) និងបានកត់សម្គាល់ពីវឌ្ឍនភាពនៃការចរចាលើក្រមប្រតិបត្តិសមុទ្រចិនខាងត្បូង (COC) និងបានគូសបញ្ជាក់ពីសារសំខាន់នៃ COC ប្រកបដោយប្រសិទ្ធភាព និងមានអត្ថន័យ ដែលស្របតាមច្បាប់អន្តរជាតិ រួមទាំង UNCLOS ឆ្នាំ១៩៨២។ នាយករដ្ឋមន្ត្រីទាំងពីរ បានបញ្ជាក់សាជាថ្មីថា នឹងបន្តកិច្ចសហប្រតិបត្តិការឆ្ពោះទៅរកការសម្រេចបាននូវ **"ឥណ្ឌូ-ប៉ាស៊ីហ្វិកសេរី និងបើកចំហ"** ដោយផ្អែក លើនីតិរដ្ឋ ដើម្បីរួមចំណែកដល់សន្តិភាព និងវិបុលភាពក្នុងតំបន់ និងពិភពលោក ។

ដំណើរទស្សនកិច្ចរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី **គីស៊ីដា** នៅព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ទៅដោយជោគជ័យ ។

សម្តេចតេជោ ហ៊ុន សែន ៖ យកចិត្តទុកដាក់អនិភាពកំពូលរបស់យើងគឺសន្តិភាព

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ពោធដាក់ឱ្យប្រើប្រាស់ ជាផ្លូវការនូវកំណាត់ផ្លូវជាតិលេខ៣ ពី ភ្នំពេញ-កំពត

✲ នៅព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ង៉ោ ង៉ិនង៉ៀង** ឯកអគ្គរដ្ឋទូតចិន ប្រចាំនៅកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ពោធដាក់ឱ្យប្រើប្រាស់ ជាផ្លូវការនូវកំណាត់ផ្លូវជាតិលេខ៣ ពី ភ្នំពេញ-កំពត ប្រវែងជាង ១៣៤គីឡូម៉ែត្រ។ **សម្តេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថា ការធ្វើឲ្យប្រសើរឡើងនូវកំណាត់ផ្លូវជាតិលេខ៣ គឺជាសមិទ្ធផលថ្មីមួយទៀត បង្ហាញឱ្យឃើញនូវកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងជោគវាសនារួមគ្នារវាងកម្ពុជា និងចិន។ សម្តេចតេជោបាន ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់រដ្ឋាភិបាល និងប្រជាជនចិន ដែលតែងតែផ្តល់ថវិកា សាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅកម្ពុជា ។ មកដល់ពេលនេះ ចិន បានផ្តល់ថវិកាសាងសង់ផ្លូវរួចរាល់នៅកម្ពុជាមានចំនួន ២៩ខ្សែ ប្រវែង ជាង ៣ពាន់គីឡូម៉ែត្រ, ផ្លូវកំពុងសាងសង់ចំនួន ៣ខ្សែ ប្រវែង ៣៦៩គីឡូ ម៉ែត្រ សាងសង់ស្ពានរួចរាល់ចំនួន ៩ស្ពាន ប្រវែង ៨.៥៦៥ម៉ែត្រ,ស្ពានកំពុងសាងសង់មានចំនួន១គឺស្ពានឆ្លងកាត់ទន្លេបាសាក់ តភ្ជាប់ផ្លូវក្រវាត់ក្រុងទី៣ ប្រវែង ៩៩៦ម៉ែត្រ តម្លៃ ៥៦លានដុល្លារ ហើយថវិកា ដែលរដ្ឋាភិបាលចិនផ្តល់សម្រាប់សាងសង់ផ្លូវ និងស្ពាន មានចំនួនជិត ៣ពាន់លានដុល្លារអាមេរិក។

ទាក់ទិនបញ្ហារុស្ស៊ី និងអ៊ុយក្រែន **សម្តេចតេជោ ហ៊ុន សែន** បានគូសបញ្ជាក់ថា គេមិនអាចយកសង្គ្រាម ទៅបញ្ចប់សង្គ្រាមបានទេនៅក្នុងបញ្ហាសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន ហើយការផ្តល់អាវុធដល់កងទ័ពអ៊ុយក្រែន មិនមែនជាជម្រើសល្អនោះទេ ព្រោះវាបង្កឲ្យកាន់តែមានការប្រយុទ្ធគ្នាបន្ថែមទៀត។ សម្តេចតេជោបានថ្លែងថា៖ ខ្ញុំបានប្រាប់នាយករដ្ឋមន្ត្រីម៉ាឡេស៊ីថា ខ្ញុំជំទាស់រាល់ការប្រើប្រាស់កម្លាំងដើម្បីប្រឆាំងនឹងភាគីមួយទៀត ហើយខ្ញុំក៏មិនគាំទ្រនូវការបំបែករដ្ឋនោះដែរ ដែលរហូតមកទល់ពេលនេះកម្ពុជាមិនទទួលស្គាល់កូសូវ៉ូនោះទេ ។ ខ្ញុំនៅតែប្រកាន់ទស្សនទានរបស់ខ្ញុំ គឺសង្គ្រាមនឹងមិនអាចបញ្ចប់សង្គ្រាមបាននោះឡើយ។ ជំហររបស់យើងតាំងពីដើមរហូតដល់ចប់ មិនគាំទ្រការយកកម្លាំង ឬការគំរាមកំហែងពីភាគីមួយប្រឆាំងនឹងភាគីមួយនោះទេ។ នេះជាទស្សនៈផ្ទាល់របស់ខ្ញុំមិនមែនជាទស្សនៈរបស់អាស៊ាននោះទេ។ **សម្តេចតេជោ ហ៊ុន សែន** បន្តថា ឥឡូវជម្លោះនេះកំពុងក្លាយជាអឺរ៉ុបរួបនីយកម្មសង្គ្រាមជាមួយរុស្ស៊ី ដែលពីមុនគឺជាការវាយប្រហារពីរុស្ស៊ីទៅកាន់អ៊ុយក្រែន ប៉ុន្តែឥឡូវនេះ ប្រទេសនានានៅក្នុងអឺរ៉ុបបាននាំគ្នាផ្តល់មនុស្សផ្តល់អាវុធ ផ្តល់យន្តហោះចម្បាំង ដើម្បីវាយតបរុស្ស៊ី ។ បើដូច្នេះសង្គ្រាមរវាងអ៊ុយក្រែន និងរុស្ស៊ី មិនមែនជាសង្គ្រាមអ៊ុយក្រែន និងរុស្ស៊ី ទៀតទេ ជាសង្គ្រាមរវាងរុស្ស៊ី និងអឺរ៉ុបតាមរយៈការផ្តល់ជំនួយយោធា ដែលជាការលើកទឹកចិត្តបន្ថែមក្នុងការធ្វើសង្គ្រាម ។ សម្តេចតេជោបញ្ជាក់ទៀតថា៖ គោលជំហរផ្លូវការរបស់យើងសម្រាប់ក្របខណ្ឌអាស៊ាននឹងមើលទៅតាមការវិវត្តន៍នៃសភាពការណ៍ យើងមិនដាក់ការប្រដៅចំពោះប្រទេសណាទាំងអស់ ប៉ុន្តែយើងគ្រាន់តែបញ្ជាក់ពីគោលជំហររបស់យើង, យើងលើកទឹកចិត្តឲ្យមានការចរចា។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងអំណរគុណដល់គ្រប់តួអង្គទាំងអស់ដែលបានគាំទ្រ សម្តេចក្នុងឋានៈជាប្រធានអាស៊ានឆ្នាំ ២០២២ ប្រកបដោយការលើកចិត្ត និងក្នុងន័យស្ថាបនា ដែលនឹងធ្វើឲ្យកម្ពុជាអាចសម្រេចជោគជ័យរួមជាមួយសហគមន៍អន្តរជាតិ ក៏ដូចជាដៃគូក្នុងតំបន់អាស៊ាន ដើម្បីធានាជោគជ័យនៃការដោះស្រាយបញ្ហានានា» ។

✲ នៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ង៉ោ ង៉ិនចាន** ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ ដែលជាជំនួយឥតសំណងរបស់រដ្ឋាភិបាល និងប្រជាជនចិន ជូនចំពោះរដ្ឋាភិបាល និងប្រជាជនកម្ពុជា និងសម្ពោធអាគារសាលាបឋមសិក្សា និងវិទ្យាល័យតេជោសែន ត្បូងឃ្មុំ ផងដែរ ។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ នេះគឺជាសមិទ្ធផលថ្មីមួយទៀតរបស់ប្រទេសកម្ពុជា ក្រោមចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អ រវាងកម្ពុជា និងចិន ។ អគារដ៏ស្តឹមស្តែនៃមន្ទីរពេទ្យនេះ នឹងឆ្លើយតបកាន់តែប្រសើរឡើងសម្រាប់ការគាំពារសុខុមាលភាពប្រជាពលរដ្ឋ មិនថាតែនៅក្នុងខេត្តត្បូងឃ្មុំខ្លួនឯងប៉ុណ្ណោះនោះទេ តែវាអាចបម្រើដល់ខេត្តផ្សេងៗទៀត ដែលនៅភូមិភាគនេះ ដូចជាខេត្តព្រៃវែង ក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី និងរតនគិរីជាដើម ក៏អាចមកទទួលសេវាព្យាបាលជំងឺផ្សេងៗនៅមន្ទីរពេទ្យនេះ សម្តេចតេជោបានថ្លែងថា តាមរយៈវត្តមានមន្ទីរពេទ្យទាំងអស់នេះ បានបង្ហាញឱ្យឃើញពីការយកចិត្តទុកដាក់លើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។ ពិតមែនតែកម្ពុជាមានការខ្វះខាតនូវបរិក្ខារទំនើបៗសម្រាប់ព្យាបាលប្រជាពលរដ្ឋ ប៉ុន្តែកម្ពុជាមិនខ្វះនូវទឹកចិត្តសម្រាប់ការលើកកម្ពស់នូវសុខុមាលភាព របស់ប្រជាពលរដ្ឋនោះទេ។ មន្ទីរពេទ្យមានបរិក្ខារទំនើបជារឿងសំខាន់ តែអ្វីកាន់តែសំខាន់ទៀតនោះ គឺមនសិការវិជ្ជាជីវៈរបស់ក្រុមគ្រូពេទ្យ ។ ទាក់ទិនទៅនឹងវ៉ាក់សាំងការពារជំងឺកូវីដ-១៩ សម្តេចតេជោថ្លែងថា វ៉ាក់សាំងគឺជាដង្កើមសេដ្ឋកិច្ចរបស់កម្ពុជា ព្រោះបើគ្មានការចាក់វ៉ាក់សាំង ភាពសាំក្នុង

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនត្បូងឃ្មុំ

សហគមន៍មិនអាចកើតមានឡើយ ហើយសកម្មភាពសេដ្ឋកិច្ច ក៏មិនអាចដំណើរការបានដែរ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងឲ្យដឹងថា សម្តេចប្រើពេលតែជាង ៣ ម៉ោងប៉ុណ្ណោះ ក្នុងការសម្រេចចិត្តធ្វើជាសហស្ថានិកនៃមហាសន្និបាតអង្គការសហប្រជាជាតិ (UN) លើបញ្ហាសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន។ **សម្តេចតេជោ ហ៊ុន សែន** បានបញ្ជាក់ថា «យើងបានតាមដានមើលសភាពការណ៍ដោយដិតដល់ ប៉ុន្តែយើងឃើញថាសង្គ្រាមនេះ គឺចេះតែរុលទៅមុខ ដូច្នេះបានជាកម្ពុជាសម្រេចចិត្តចូលរួមធ្វើជាសហស្ថាបនិកនៃសេចក្តីសម្រេចចិត្តមហាសន្និបាតអង្គការសហប្រជាជាតិ ។ ខ្ញុំចេញបញ្ជាត្រឹមតែ ៣ម៉ោងកន្លះមុន ការបោះឆ្នោតតែប៉ុណ្ណោះ ព្រោះយើងមិនអាចព្រងើយកន្តើយជាមួយនឹងការវាយលុកទ្រង់ទ្រាយធំ ពីប្រទេសមួយ ចូលទៅក្នុងប្រទេសមួយទៀតបានទេ។ ហេតុនេះបានជាកម្ពុជា ត្រូវប្រកាន់យកឥរិយាបថជាក់លាក់មួយ»។ **សម្តេចតេជោ ហ៊ុន សែន** ថ្លែងថា ជម្រើសដែលល្អជាងគេនៅពេលនេះ សម្រាប់រុស្ស៊ី និងអ៊ុយក្រែន គឺការចរចា ហើយដើម្បីចរចាបាន ត្រូវចាប់ផ្តើមពីបទឈប់បាញ់។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា កម្ពុជាបានយកចិត្តទុកដាក់លើសន្តិភាពជាង ២០ឆ្នាំហើយ បើនិយាយឲ្យពិតទៅយើងបានប្រឹងប្រែង ៤០ ឆ្នាំជាងដើម្បីតែសន្តិភាពមួយនេះ ។ សម្តេចតេជោក៏បានលើកជាសំណួរថាតើយើងត្រូវបណ្តែតបណ្តោយឲ្យ មនុស្សមួយក្រុមបំផ្លាញសន្តិភាពយើងបានទេ? ប៉ុន្មានថ្ងៃនេះ នៅកម្ពុជាមានការចាប់អារម្មណ៍ខ្លាំងទៅលើសំដីរបស់ប្រធានាធិបតីអ៊ុយក្រែន ដែលបាននិយាយថា៖ «ពេលនេះអាទិភាពកំពូលរបស់អ៊ុយក្រែនគឺសន្តិភាព»។ អ្នកអត្ថាធិប្បាយរបស់យើងថានៅកម្ពុជាបានយកសន្តិភាព ធ្វើជាអាទិភាពកំពូល ។ កាលពីមុនអត់ស្រែករកសន្តិភាពទេ ស្រែករកប្រជាធិបតេយ្យ និងសិទ្ធមនុស្សដល់ពេលបាត់សន្តិភាពសិទ្ធិមនុស្សក៏បាត់ប្រជាធិបតេយ្យក៏អស់ មនុស្សក៏ស្លាប់។ សម្តេចតេជោបញ្ជាក់ថា៖ «យើងនៅទីនេះយើងយកចិត្តទុកដាក់អាទិភាពកំពូលរបស់យើងគឺសន្តិភាព ដើម្បីធានានូវសិទ្ធិរស់រានមានជីវិត បើមានសិទ្ធិរស់រានមានជីវិតហើយ គឺសិទ្ធិបញ្ចេញមតិ, ប្រជាធិបតេយ្យ និងសិទ្ធិមនុស្សត្រូវបានធានា បើស្លាប់ហើយតើបានអីធានាទៀត?»។

❋ នៅព្រឹកថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីសម្ពោធដាក់ឱ្យប្រើប្រាស់ **«ភូមិកុមារ** SOS» ស្ថិតនៅក្នុងខេត្តព្រៃវែង។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា កម្ពុជាបានធ្វើការងារច្រើនទាក់ទងទៅនឹងបញ្ហាកុមារ។ នៅលើពិភពលោកមានកុមាររងគ្រោះជាច្រើនដោយហេតុការណ៍ផ្សេងៗ ដូចជាកម្ពុជាជាដើមដោយសារតែរបបប្រល័យពូជសាសន៍ ប៉ុល ពត ក៏បានបន្សល់នូវកុមារកំព្រាជាច្រើន។ តែក្រោយពីសង្គ្រាមបានបញ្ចប់ កម្ពុជាពិតជាមានមោទនភាពចំពោះកិច្ចប្រឹងប្រែងក្នុងការជួយដល់កុមារកម្ពុជាជាបន្តបន្ទាប់ដោយមិនទុកកុមាររងគ្រោះជាបន្តទៀតឡើយ។ ជាក់ស្តែងកុមារកំព្រានៅតាមភូមិកុមារ SOS មានកុមារជាច្រើន បានក្លាយទៅជាអ្នកមានជោគវាសនាល្អ មានចំណេះដឹង កើតចេញពីការចិញ្ចឹមបីបាច់ និងការផ្តល់នូវការអប់រំនៅទីនេះ។ កុមារដែលចិញ្ចឹមបីបាច់ដោយអង្គការកុមារ SOSប្រមាណ៤នាក់បានក្លាយទៅជាវេជ្ជបណ្ឌិត៦នាក់ក្លាយជាវិស្វករ ៧នាក់បានក្លាយជាអ្នកបម្រើការនៅធនាគារ ៣នាក់ ក្លាយជាស្ថាបត្យករ ២នាក់ បានក្លាយជាអ្នករចនា និងជាច្រើននាក់ទៀត បានក្លាយជាអ្នកបម្រើការងារក្នុងវិស័យអាជីវកម្ម សេវាបម្រើអតិថិជន និងបម្រើការងារក្នុងជួររាជរដ្ឋាភិបាលផងដែរ។ ទាក់ទងទៅនឹងស្ថានភាពនៃជំងឺកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា **សម្តេចតេជោ ហ៊ុន សែន** បានប្រកាសថា ចាប់ពីពេលនេះតទៅ កម្ពុជាបានសម្រេចលុបចោលការបញ្ជាក់ធ្វើតេស្តរកជំងឺកូវីដ-១៩ តាមម៉ាស៊ីន PCR ហើយមុនចូលមកកម្ពុជារយៈពេល ៧២ម៉ោង ហើយកម្ពុជា ក៏សម្រេចលុបចោលការធ្វើតេស្តរហ័សនៅពេលដែលមកដល់កម្ពុជា និងអនុញ្ញាតឱ្យដំណើរការឡើងវិញនូវការផ្តល់ទិដ្ឋាការពេលមកដល់សម្រាប់អ្នកដំណើរអន្តរជាតិ។ ការសម្រេចនេះគឺដើម្បីសម្រួលដល់ការធ្វើដំណើរចេញចូលក្នុងប្រទេសកម្ពុជា សម្រាប់ប្រជាពលរដ្ឋ សម្រាប់ភ្ញៀវទេសចរអន្តរជាតិ និងអ្នកធ្វើធុរកិច្ចជាដើម។

❋ នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ង៉ោ ទិនឆាន** ឯកអគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវមន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ (ពេទ្យលោកសង្ឃ) ។ **សម្តេចតេជោ ហ៊ុន សែន** បានមានប្រសាសន៍ថា មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិន ព្រះកុសុមៈ កើតចេញពីចំណងមិត្តភាពនៃទំនាក់ទំនងដ៏ល្អរវាងកម្ពុជា និងចិន។ **សម្តេចតេជោ ហ៊ុន សែន** បានជំរុញឱ្យក្រសួងសុខាភិបាល សិក្សាពីលទ្ធភាពក្នុងការរៈកាត់ដើម្បីប្តូរក្រលៀននៅក្នុងប្រទេស ខណៈកម្ពុជាបច្ចុប្បន្នក៏មានសមត្ថភាពធ្វើបានដែរ គ្រាន់តែថាកន្លងមក យើងមិនមានការផ្សព្វផ្សាយឲ្យទូលំទូលាយ ព្រោះដោយសារតែខ្លាចមានការជួញដូរក្រលៀន ឬអវយវៈ។ ការបង្កើនសមត្ថភាពរបស់គ្រូពេទ្យគឺជារឿងសំខាន់ បូកនឹងការពង្រឹងបន្ថែមទៀតនូវក្រមសីលធម៌វិជ្ជាជីវៈពេទ្យ ដើម្បីធានាការព្យាបាលមានប្រសិទ្ធភាព និងសុវត្ថិភាព។ **សម្តេចតេជោ ហ៊ុន សែន** បានថ្លែងថា មិត្តចិនបានប្រកាសផ្តល់ជំនួយបន្ថែមនូវវ៉ាក់សាំងបង្ការជាជំងឺកូវីដ-១៩ ចំនួន ២០លានដូសបន្ថែមទៀត ដោយ ៥ លានដូសនឹងមកដល់ក្នុង

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីសម្ពោធដាក់ឱ្យប្រើប្រាស់ «ភូមិកុមារ SOS» ស្ថិតនៅ ក្នុងខេត្តព្រៃវែង

ពេលឆាប់ៗនេះ ដូច្នេះតាមរយៈជំនួយវ៉ាក់សាំងបន្ថែមទៀតនេះ ធ្វើឱ្យកម្ពុជាបានទទួលវ៉ាក់សាំងសម្រាប់ចាក់ជូនប្រជាពលរដ្ឋការពារជំងឺកូវីដ-១៩ បានគ្រប់គ្រាន់។

❋ នៅរសៀលថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ នៅសណ្ឋាគារ រ៉ស៊ីដង់ សុខាភ្នំពេញ។ **សម្តេចតេជោ ហ៊ុន សែន** បានវាយតម្លៃខ្ពស់ចំពោះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលបានបំពេញតួនាទីដឹកនាំនិងសម្របសម្រួលកិច្ចការជាទូទៅនៃកម្មវិធីកែទម្រង់រឹមជ្ឈការ និងវិសហមជ្ឈការសម្រេចបានសមិទ្ធផលគួរជាទីមោទនៈ។

នៅក្នុងឱកាសនោះ **សម្តេចតេជោ ហ៊ុន សែន** បានផ្តល់នូវអនុសាសន៍សំខាន់ៗមួយចំនួន គឺត្រូវបន្តលើកកម្ពស់ប្រសិទ្ធភាព និងចីរភាពនៃការគ្រប់គ្រងការងារកែទម្រង់ត្រូវបន្តបែងចែកឱ្យបានច្បាស់លាស់នូវតួនាទីសិទ្ធិអំណាច និងការទទួលខុសត្រូវលើការផ្តល់សេវាសាធារណៈដែលត្រូវបានផ្ទេរពីក្រសួង ស្ថាប័នថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសរវាងថ្នាក់រដ្ឋបាលនីមួយៗដើម្បីរៀបចំគោលនយោបាយ និងការផ្តល់សេវាក្នុងវិស័យនីមួយៗ។ បន្តពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិបន្ថែមទៀត តាមរយៈការរៀបចំឡើងវិញនូវមុខងាររចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ក្នុងការផ្តល់សេវាទាន់ពេលវេលាជូនប្រជាពលរដ្ឋ។ រដ្ឋបាលរាជធានីភ្នំពេញត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រង និងមុខងារស្របតាមចរិតលក្ខណៈជាទីក្រុងធំដែលហៅជាសកលថា **"ទីក្រុងមេត្រ្ចប៉ូលីតែន"** ដើម្បីធានាដោះស្រាយនូវរាល់បញ្ហាប្រឈមនានាដែលជាតម្រូវការសមស្របតាមកំណើនប្រជាជន និងសេវាទីក្រុង។ រដ្ឋបាលខេត្តត្រូវបន្តរៀបចំ ឱ្យមានរចនាសម្ព័ន្ធគ្រប់គ្រង និងមុខងារស្របតាមចរិតលក្ខណៈរដ្ឋបាលតំបន់ដែលតំណាងឱ្យរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នថ្នាក់ជាតិហើយត្រូវគាំទ្រតាមដានត្រួតពិនិត្យលើការបំពេញការងាររដ្ឋបាលមូលដ្ឋាន ការផ្តល់សេវាសាធារណៈជាមួយនឹងការគ្រប់គ្រងគម្រោងអភិវឌ្ឍន៍ដែលមានលក្ខណៈបច្ចេកទេសខ្ពស់ ហើយដែលក្រុង ស្រុក មិនអាចមានលទ្ធភាពអនុវត្តបាន។ ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តពិនិត្យ និងកែលម្អគោលការណ៍ និងកម្មវិធីនានាដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សដើម្បីលើកទឹកចិត្តការបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការផ្តល់ថវិកាបន្ថែមលើបៀវត្ស និងការឧបត្ថម្ភផ្សេងៗ ការដំឡើងកម្រិតថ្នាក់ និងឋានន្តរស័ក្តក្នុងមុខតំណែងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យសមស្របទៅនឹងមុខជំនាញ ដើម្បីធានាការគ្រប់គ្រងធនធានមនុស្សប្រកបដោយប្រសិទ្ធភាពយុត្តិធម៌ និងគ្មានការរើសអើង។ អំពីធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបន្តខិតខំពង្រឹងការគ្រប់គ្រងការប្រមូលចំណូលជាមួយនឹងការគ្រប់គ្រងចំណាយប្រកបដោយតម្លាភាព។ គ្រប់ស្ថាប័នទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវកាត់បន្ថយចំណាយដែលពុំមានតម្រូវការចាំបាច់រួមទាំងគម្រោងវិនិយោគសាធារណៈ ដែលពុំទាន់ចាំបាច់ដើម្បីធានាស្ថិភាពវិកាជាតិដែលកំពុងស្ថិតក្នុងស្ថានភាពលំបាកដោយសារជំងឺកូវីដ-១៩។

មន្ទីរពេទ្យមិត្តភាពកម្ពុជា-ចិនព្រះកុសុមៈ (ពេទ្យលោកសង្ឃ)

❋ នៅព្រឹកថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយ ឯកឧត្តម Park Heung-kyeong អគ្គរដ្ឋទូតកូរ៉េប្រចាំនៅកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ២១ប្រវែងជិត៦៤គីឡូម៉ែត្រតភ្ជាប់ពីរង្វង់មូលក្រុងតាខ្មៅរហូតដល់ច្រកទ្វារអន្តរជាតិកម្ពុជា-វៀតណាម (ជ្រៃធំ-ឡុងប៊ិញ) ក្នុងខេត្តកណ្តាល។

សម្តេចតេជោ ហ៊ុន សែន បានលើកឡើងថា ឥទ្ធិពលសង្គ្រាមរុស្ស៊ី-អ៊ុយក្រែនបានមកដល់ប្រទេសកម្ពុជាហើយក្នុងនោះបណ្តាលឱ្យប្រេងឡើងថ្លៃ។ បញ្ហាដែលកើតចេញពីសង្គ្រាមនេះ មានភាពខ្លាំងក្លាជាងវិបត្តកូវីដ១៩ ហើយមិនអាចព្យាករណ៍បានថា ពិភពលោកនឹងដើរដល់សង្គ្រាមលោកលើកទី៣ ឬដើរដល់សង្គ្រាមនុយក្លេអ៊ែរឬយ៉ាងណាទេ? ប៉ុន្តែកម្ពុជាអំពាវនាវឱ្យមានបទឈប់បាញ់ និងចរចាដើម្បីស្រុះស្រួលបញ្ឈប់សង្គ្រាមនេះ។ សម្តេចតេជោបានបន្តថា «យើងផ្តល់ការគាំទ្រទាំងឡាយ ដែលនាំមកនូវសន្តិភាព ហើយយើងក៏មិនយកសាំងទៅចាក់លើភ្លើងដែរ»។

❋ នៅរសៀល ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់នៅក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សម្តេចតេជោ ហ៊ុន សែន បានចេញបទបញ្ជាដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរខេត្តជុំវិញបឹងទន្លេសាបឱ្យបង្ក្រាបក្រុមឈ្មួញទុច្ចរិតដែលប្រព្រឹត្តបទល្មើសនេសាទបំផ្លាញត្រីនៅលើផ្ទៃបឹងទន្លេសាបឱ្យអស់

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ ឆ្នាំ២០២១ ដល់ឆ្នាំ២០៣០

សម្តេចតេជោ ហ៊ុន សែន អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ២១

ត្រូវចាប់ ក្រុមប្រព្រឹត្តបទល្មើសជលផលខ្នាតធំមកផ្តន្ទាទោសតាមផ្លូវច្បាប់ ដើម្បីធានាឲ្យបាននិរន្តរភាពធនធានជលផលនៅកម្ពុជា ។ **សម្តេចតេជោ ហ៊ុន សែន** ក៏បានណែនាំឱ្យគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធជាពិសេស អាជ្ញាធរខេត្ត ជុំវិញបឹងទន្លេសាប ធ្វើការរៀបចំដាំកូនឈើលើផ្ទៃដីជាង៦ម៉ឺន ហិកតា ដែលប្រជាពលរដ្ឋបានប្រគល់មកវិញនោះឡើងវិញ និង ធ្វើការថែទាំជាប្រចាំ ធ្វើយ៉ាងណាហាមផ្តាច់មិនឱ្យមានសកម្មភាព ទន្ទ្រានដីព្រៃលិចទឹកបឹងទន្លេសាបកើតឡើងវិញ ដើម្បីឱ្យកូនឈើទាំងនោះធំលូតលាស់ក្លាយជាព្រៃលិចទឹក សម្រាប់ជាទីជម្រកមច្ចជាតិក្នុងអំឡុងពេល៣ឆ្នាំខាងមុខ។

✵ នៅព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា រួមជាមួយ ឯកឧត្តម ទីប្រឹក្សាស្ថានទូតចិនប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្តោធដាក់ឱ្យប្រើប្រាស់ផ្លូវជាតិលេខ៥១។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា ផ្លូវជាតិលេខ៥១ នេះគឺជាផ្លូវខ្សែក្រវាត់ភ្នំពេញមួយ ដែលបានជួយសម្រួលការធ្វើដំណើរជាពិសេសអ្នកដែលរស់នៅដូចជាខេត្តបាត់ដំបងពោធ៏សាត់ កំពង់ឆ្នាំងជាដើម ដែលមានបំណងចង់ទៅខេត្តតំបន់មាត់សមុទ្រ មិនចាំបាច់ឆ្លងកាត់រាជធានីភ្នំពេញទេ គេអាចធ្វើដំណើរកាត់តាមផ្លូវជាតិលេខ ៥១នេះ។ ផ្លូវនេះ គឺជាផ្លូវយុទ្ធសាស្ត្រមួយរបស់រាជរដ្ឋាភិបាលកម្ពុជានាពេលបច្ចុប្បន្ន ក្នុងការតភ្ជាប់ទៅកាន់សមុទ្រកម្ពុជា។ បច្ចុប្បន្នកិច្ចសហប្រតិបត្តិការវាងកម្ពុជា និងចិន កំពុងផ្តល់ផ្លែផ្កាជាច្រើនទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការធ្វើពាណិជ្ជកម្មនិងការវិនិយោគ។ជំងឺកូវីដ-១៩មិនអាចរារាំងដំណើរការអភិវឌ្ឍរបស់កម្ពុជាបានឡើយ ក្នុងនោះគម្រោងនានា របស់ចិន ក៏មិនមានការផ្អាកសកម្មភាពនោះដែរ។ សមិទ្ធផលទាំងអស់នេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងក្នុងការបិទបញ្ចប់ភ្លើងសង្ត្រាម និងការរកសុខសន្តិភាពជូនជាតិមាតុភូមិ។ ទោះបីក្នុងលក្ខខណ្ឌណាក៏ដោយ យើងត្រូវរួមគ្នារក្សាឱ្យបាននូវសុខសន្តិភាព។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងថា៖ «នៅឆ្នាំ២០២៣ ខ្ញុំនឹងបន្តក្នុងឋានៈ ជាបេក្ខជននាយករដ្ឋមន្ត្រីនៃការបោះឆ្នោតជាបន្តទៀត ព្រោះនេះជាកិច្ចការដែលយើងត្រូវបន្ត។ រឿងផ្លាស់ប្តូរនៅពេលណាចាំបោះឆ្នោតរួចចាំ និយាយគ្នាត្រូវបន្តព្រោះយើងមិនអាចធ្វេសប្រហែសជាមួយ នឹងការកិច្ចការទាក់ទងនឹងការរក្សាសន្តិភាពបានទេ»។

✵ នៅព្រឹកថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម Park Heung kyeong ឯកអគ្គរដ្ឋទូតកូរ៉ែប្រចាំនៅកម្ពុជា បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារមជ្ឈមណ្ឌលត្រចៀកច្រមុះបំពង់កនៃមន្ទីរពេទ្យព្រះអង្គខួង។

សម្តេចតេជោ ហ៊ុន សែន ថ្លែងថា ឆ្នាំនេះជាខួប ២៥ឆ្នាំនៃទំនាក់ទំនងកម្ពុជា និងសាធារណៈរដ្ឋកូរ៉ែ ។ អគារព្យាបាលជំងឺត្រចៀក ច្រមុះ និងបំពង់ក មិត្តភាពកម្ពុជា-កូរ៉ែ នេះគឺជាសមិទ្ធផលកើតចេញពីទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការល្អ រវាងកម្ពុជា និងកូរ៉ែ។ ក្នុងនាមជាស្ថាបនិកនៃការភ្ជាប់ឡើងវិញនៃទំនាក់ទំនងប្រទេសទាំង២ សម្តេចតេជោពិតជាមានមោទនភាពចំពោះទំនាក់ទំនងនេះ ដែលនាំឲ្យកើតមាននូវសមិទ្ធផលជាច្រើនសម្រាប់ជាតិ ។ ទាក់ទងទៅនឹងស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា សម្តេចតេជោបានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំក្រសួងសុខាភិបាល និងគ្រូពេទ្យនៅទូទាំងប្រទេស ដែលបានប្រឹងប្រែងជំនះការរីករាលដាលជំងឺកូវីដ-១៩ រយៈពេល ២ឆ្នាំកន្លងទៅនេះ។ វេលាពេលនេះកាលពីឆ្នាំ២០២១ គឺជាពេលដ៏លំបាកសម្រាប់កម្ពុជា ដោយសារការឆ្លងជំងឺកូវីដ-១៩មានការផ្ទុះខ្លាំង ជាពិសេសនៅក្នុងព្រឹត្តិការណ៍សហគមន៍២០ កុម្ភៈ ដែលពេលនោះមានមនុស្សស្លាប់ និងមានអ្នកសម្រាកនៅមន្ទីពេទ្យជាបន្តបន្ទាប់ តែឆ្នាំនេះយើងមានស្ថានភាពល្អប្រសើរ ទាំងនេះដោយសារតែយុទ្ធសាស្ត្រនៃការចាក់ស្រោចវ៉ាក់សាំងរបស់យើងបានទាន់សភាពការណ៍។

សម្តេចតេជោ ហ៊ុន សែន បានអះអាងថា ទោះបីប្រទេសរុស្សីជាមិត្តល្អជាមួយនឹងកម្ពុជា ហើយក៏ធ្លាប់បានជួយដល់កម្ពុជា តែកម្ពុជានៅតែប្រកាន់គោលជំហរថ្កោលទោស ជាដាច់ខាតចំពោះការឈ្លានពានរបស់រុស្សីទៅលើប្រទេសអ៊ុយក្រែន។ សម្តេចតេជោបានថ្លែងថា ៖ «រុស្សីធ្លាប់ជួយយើង ធ្លាប់មានទំនាក់ទំនងពីទសវត្ស ៥០រហូតដល់មកសព្វថ្ងៃ ប៉ុន្តែរុស្សីបានឈ្លានពានអ៊ុយក្រែន។ យើងបានបោះឆ្នោតប្រឆាំងរុស្សី និងថ្កោលទោសការឈ្លានពានរបស់រុស្សីទៅអ៊ុយក្រែនចំនួន ២លើកមកហើយ។ ខ្ញុំសុំបញ្ជាក់ថា កម្ពុជាប្រកាន់ជំហរជាគោលការណ៍មិនថាតែប្រទេសរុស្សីទេ ប្រទេសណាក៏ដោយឲ្យតែឈ្លានពានទៅកាន់ប្រទេសមួយទៀត កម្ពុជាប្រឆាំងជានិច្ច។ សម្តេចតេជោបន្តថា ប្រទេសទាំងអស់ត្រូវតែគោពអធិបេតេយ្យភាពឯករាជ្យ និងអធិបតេយ្យ-ភាពរបស់ប្រជាជាតិនានា។ ការគោរពឯករាជ្យអធិបតេយ្យភាពរបស់ប្រទេសអ៊ុយក្រែន គឺមានតម្លៃស្មើនឹងការគោរពឯករាជ្យអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាដែរ។

សម្តេចក្រឡាហោម ស ខេង ៖ យើងត្រូវផ្តោតលើអតិក្រម រួមគិត រួមធ្វើ និង រួមទទួលខុសត្រូវសំដៅទទួលបានសេវាសាធារណៈប្រកបដោយគុណភាពនិងប្រសិទ្ធភាព

សម្តេចក្រឡាហោម ស ខេង អញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តជាផ្លូវការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០)

នៅព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២២ **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តជាផ្លូវការកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០)។

ក្នុងឱកាសនោះ **សម្តេចក្រឡាហោម ស ខេង** បានលើកឡើងថា ការប្រារព្ធពិធីនេះឡើងគឺ មានគោលបំណងប្រកាសផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តជាផ្លូវការនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០ ដែលរាជរដ្ឋាភិបាលបានអនុម័តកាលពីថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២១ ដើម្បីលើកកម្ពស់ការយល់ដឹងឲ្យបានទូលំទូលាយក្នុងចំណោមអ្នកពាក់ព័ន្ធនានា បង្កើនការទទួលខុសត្រូវ និងការចូលរួមគាំទ្រដល់ការអនុវត្តកម្មវិធីជាតិ ដំណាក់កាលទី២នេះ។ សម្តេចក្រឡាហោមបានគូសបញ្ជាក់អំពីកិច្ចដំណើរការនៃការអនុវត្តកំណែទម្រង់ វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងប្រទេសកម្ពុជា និងកំណត់សម្គាល់អំពីប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសាធារណៈ ដែលក្នុងនោះប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការពិតជាមានគុណសម្បត្តិល្អប្រសើរច្រើនដោយសារប្រព័ន្ធនេះបានផ្តល់ការទទួលខុសត្រូវ និងភាពជាម្ចាស់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅកៀកជិតប្រជាពលរដ្ឋ ដើម្បីធ្វើសេចក្តីសម្រេចចិត្តក្នុងការផ្តល់សេវាសាធារណៈចាំបាច់នានាដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

សម្តេចក្រឡាហោម ស ខេង បានថ្លែងថា «និយាយដោយសាមញ្ញ គឺរដ្ឋបាលដែលនៅកៀកជិត ប្រជាពលរដ្ឋអាចដឹងសុខទុក្ខ និងតម្រូវការពិតប្រាកដរបស់ប្រជាពលរដ្ឋបានយ៉ាងច្បាស់ និងត្រឹមត្រូវជាងរដ្ឋបាលដែលនៅឆ្ងាយពីប្រជាពលរដ្ឋ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិទាំងនេះក៏អាចរៀបចំផែនការ អាចមានមធ្យោបាយដោះស្រាយបញ្ហាប្រឈមនានា និងអាចធ្វើសេចក្តីសម្រេចចិត្ត ដ៏ត្រឹមត្រូវក្នុងការឆ្លើយតបទៅនឹងសំណើសំណូមពរ និងតម្រូវការនានារបស់ប្រជាពលរដ្ឋបានយ៉ាងសមស្រប ឆាប់រហ័ស និងមានប្រសិទ្ធភាពខ្ពស់ស្របតាមស្ថានភាព ជាក់ស្តែងដែលមានលក្ខណៈខុសគ្នាៗនៃមូលដ្ឋាននីមួយៗ ។ សម្តេចក្រឡាហោមបានលើកឡើងនូវមូលហេតុសំខាន់ៗធំៗចំនួន៣ ដែលរាជរដ្ឋាភិបាលសម្រេចចិត្តរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជារួមមាន៖ **១**-ដើម្បីពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សតាមរយៈការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានការចូលរួមពីគណបក្សនយោបាយជាច្រើន ដើម្បីពង្រឹង សន្តិភាព ស្ថិរភាពនយោបាយ សម្រាប់ជាកាលានុវត្តភាព ក្នុងការកសាងជាតិឡើងវិញ, **២**-ដើម្បីលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការផ្ទេរនូវសិទ្ធិអំណាច មុខងារ ធនធាន និងការទទួលខុសត្រូវទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលនៅកៀកជិតប្រជាពលរដ្ឋ និង**៣**-ដើម្បីជំរុញ និងលើកកម្ពស់ការចូលរួមនានានៅមូលដ្ឋានតាមរយៈការបំផុសឱ្យមាននូវគំនិតផ្តួចផ្តើម និងច្នៃប្រឌិតដ៏សម្បូរណ៍បែបនៃការដឹកនាំរបស់អាជ្ញាធរមូលដ្ឋាន ព្រមទាំងការចូលរួមមតិយោបល់ និងការផ្តល់មូលនិធិនានារបស់ប្រជាពលរដ្ឋនៅក្នុងការអភិវឌ្ឍមូលដ្ឋាននីមួយៗ។

សម្តេចក្រឡាហោមក៏បានបញ្ជាក់អំពីសមិទ្ធផលធំៗពីរ ដែលសម្រេចបានឆ្លើយតបទៅនឹងចក្ខុវិស័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រួមមាន **ទី១**-ផ្អែកលើការសម្របសម្រួលឯកភាពស្រុះស្រួលគ្នាខាងនយោបាយ បានរៀបចំធ្វើការបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និង**ទី២**-ការសម្រេចបាននូវការលើកកម្ពស់ប្រសិទ្ធភាពនិងគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន តាមរយៈការផ្ទេរមុខងារ និងធនធានក្នុង វិស័យអាទិភាពនានាជាបណ្តើរៗទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជាមួយនេះ សម្តេចក្រឡាហោមក៏បានកត់សម្គាល់ពីបញ្ហាប្រឈមមួយចំនួនដែលត្រូវរួមគ្នាពិនិត្យ និងដោះស្រាយ ដូចជាការធានាឱ្យមានការស្រុះស្រួលមូលគំនិតគ្នាអំពីការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ រចនាសម្ព័ន្ធ និងប្រព័ន្ធនៅមិនទាន់មានលក្ខណៈសមស្រប ការចូលរួមរបស់សង្គមស៊ីវិល និងវិស័យឯកជននៅពុំទាន់ពេញលេញ និងមាននិរន្តរភាព ខណៈការធ្វើឱ្យមានការផ្លាស់ប្តូរផ្នត់គំនិត និងរបៀបរបបបំពេញការងាររបស់មន្ត្រីទៅតាមបែបបទថ្មីនៃកំណែទម្រង់ក៏ជាបញ្ហាប្រឈមដ៏សំខាន់មួយដែលតម្រូវឱ្យបន្តប្រើប្រាស់ពេលវេលាបន្តទៀតដើម្បីដោះស្រាយផងដែរ៕

សម្តេចពិជ័យសេនា ទៀ បាញ់ ៖ ពង្រឹងស្មារតីសាមគ្គីភាព បន្តកាន់ទង់សន្តិភាពតកូនតចៅទៅមុខទៀត

សម្តេចពិជ័យសេនា ទៀ បាញ់ និងលោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបញ្ចុះបឋមសិលា និងបើកការដ្ឋានសាងសង់ស្តូប ឈ្នះ-ឈ្នះ អន្លង់វែង

នៅព្រឹកថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ **សម្តេចពិជ័យសេនា ទៀ បាញ់** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី និង**លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** អនុប្រធានគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបញ្ចុះបឋមសិលា និងបើកការដ្ឋានសាងសង់ស្តូប ឈ្នះ-ឈ្នះ អន្លង់វែង ដែលស្ថិតនៅភ្នំ២០០ ឃុំត្រពាំងប្រីយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ ក្នុងឱកាសនោះ **សម្តេចពិជ័យសេនា ទៀ បាញ់** បានថ្លែងថា គោលនយោបាយឈ្នះ-ឈ្នះ បានផ្តល់គំនិត មេរៀនបទពិសោធន៍ ដល់ប្រទេសដទៃទៀត ពិសេសព្រោះគោលនយោបាយនេះ មានប្រសិទ្ធភាពក្នុងការបញ្ចប់ជម្លោះផ្នែកនយោបាយ និងយោធានៅថ្នាក់មូលដ្ឋាន ។ សម្តេចពិជ័យសេនាបានបន្តថា រឿងរ៉ាវជាច្រើនដែលរកបាននៅទីនេះ គឺការរួមចំណែកនៃប្រតិបត្តិករទាំងអស់ទាំងកងយោធពលខេមរភូមិន្ទ ស្ថាប័ននានា និងទាំងអតីតកងកម្លាំងកម្ពុជាប្រជាធិបតេយ្យដែលកំពុងនៅទីនេះ ក្នុងស្មារតីសាមគ្គីភាព បន្តកាន់ទង់សន្តិភាពតកូនតចៅទាំងអស់គ្នាតទៅមុខទៀត។ នេះហើយគឺជាខឿនការពារជាតិជាប្រវត្តិសាស្ត្រដែលមិនអាចកាត់ថ្លៃបាន និងដំណើរសន្តិភាពរបស់យើងដូចសម្តេចតេជោបានបញ្ជាក់ថា **«មានសន្តិភាពទើបមានក្តីសង្ឃឹម»** ។ សន្តិភាព ដែលបានដោយនយោបាយឈ្នះ-ឈ្នះ គឺជាស្នាដៃស្ថាបនិកមគ្គុទេសក៍ឯក និងប្រតិបត្តិករឯកដែលយើងខិតខំធ្វើនៅថ្ងៃនេះ។

សម្តេចពិជ័យសេនា ទៀ បាញ់ បានថ្លែងថា៖ តំបន់ប្រវត្តិសាស្ត្រយោធាទាំងអស់ ដែលបានរៀបចំ និងទទួលបានការអនុម័ត កំពុងដំណើរការ ដូចជាតំបន់ភ្នំ២០០ សម្តេចតេជោធ្លាប់បានបញ្ជាក់ជាច្រើនលើកអំពីការចាប់ផ្តើមរបស់យើងនៅភ្នំ២០០ នេះ ។ ជាមួយគ្នានេះ ក្រុមការងារបានរៀបចំតំបន់ថ្មីមួយទៀត ដែលជាកិច្ចការត្រូវធ្វើខានមិនបាន នោះគឺបុព្វហេតុនៃសកម្មភាព ដែលដំណើរការមកដល់តំបន់នេះ ក្នុងដំណើរការអនុវត្តគោលនយោបាយ ឈ្នះ-ឈ្នះ ចុងក្រោយគឺតំបន់អណ្តូង៣ នៅស្រែណូយ ព្រៃស្អាក។ ដើម្បីដំណើរការរៀបចំនៅតំបន់នេះបាន សូមឲ្យរដ្ឋអំណាចមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធសហការព្រោះទីនោះគឺជាតឹកតាងមួយដ៏សំខាន់ មុននឹងមកដល់តំបន់ភ្នំ២០០។ អ្វីទាំងអស់នេះអាចកសាងជាខ្សែរភាពយន្តប្រវត្តិសាស្ត្រនៅពេលខាងមុខនឹងត្រូវបានចារឹក ជាចម្លាក់តាមជញ្ជាំងនៃស្តូប ឈ្នះ-ឈ្នះ នៅទីនេះ។ **សម្តេចពិជ័យសេនា ទៀ បាញ់** ក៏បានបញ្ជាក់ថា៖ ការកែប្រែតំបន់នេះទៅជាតំបន់ប្រវត្តិសាស្ត្រយោធា មិនមែនមានន័យថា ជាកិច្ចការសម្រាប់តែផ្នែកកងទ័ពនោះទេ ប៉ុន្តែគឺជាមូលដ្ឋាននៃការបង្កើត និងពង្រីកសក្តានុពលនៃវិស័យសេដ្ឋកិច្ច-សង្គម ប្រវត្តិសាស្ត្រ ទេសចរណ៍ វប្បធម៌ សន្តិសុខ និងការការពារបូរណភាពទឹកដីថែមទៀតផងដែរ។ នៅទីនេះទោះបីជាកសាងយ៉ាងណាក៏មិនអាចដល់ទីបញ្ចប់ ឬគ្រប់គ្រាន់ដែរ។ ភាពចាំបាច់របស់យើងគឺជានានិរន្តរភាព និងត្រូវធ្វើជាបន្តបន្ទាប់ ដោយស្មារតីនៃការចូលរួមដើម្បីតបស្នងសងគុណ និងបង្ហាញពីការដឹងគុណចំពោះសន្តិភាព។

នៅក្នុងឱកាសនោះ **សម្តេចពិជ័យសេនា ទៀ បាញ់** ក៏ធ្វើការណែនាំដល់អនុគណៈកម្មការសាងសង់ស្តូបឈ្នះ-ឈ្នះ និងអាជ្ញាធរពាក់ព័ន្ធនូវកិច្ចការមួយចំនួន រួមមាន ៖ បន្តអនុវត្តស្មារតីសិក្ខាសាលានៅថ្ងៃ៧-៨ ខែមករា ឆ្នាំ២០២០ ឲ្យបានគ្រប់ជ្រុងជ្រោយ ពង្រឹងពង្រីកនូវការយល់ដឹងការចូលរួមសម្រាប់ការលើកកម្ពស់គោលនយោ បាយឈ្នះ-ឈ្នះ មគ្គុទេសភាព របស់សម្តេចតេជោ និងតឹកតាងប្រវត្តិសាស្ត្រនានា នៅក្នុងការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ។ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវចូលរួមចំណែកគាំទ្រដល់ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ជុំវិញតំបន់អភិវឌ្ឍន៍នេះតាមសំណូមពរចាំបាច់របស់អនុគណៈកម្មការសាងសង់ស្តូបឈ្នះ-ឈ្នះអន្លង់វែង ដើម្បីលើកកម្ពស់សោភ័ណ្ឌភាពស្តូប និងតំបន់រណបឲ្យកាន់តែប្រសើរឡើង ដែលជាការទាក់ទាញភ្ញៀវទេសចរណ៍មកចូលរួមទស្សនាកំសាន្ត។ អនុគណៈកម្មការសាងសង់ស្តូប ឈ្នះ-ឈ្នះ ត្រូវសហការជាមួយផ្នែកការងារពាក់ព័ន្ធទាំងអស់ ខិតខំសិក្សា ស្រាវជ្រាវឯកសារ ភស្តុតាង តឹកតាង ខ្លឹមសារប្រវត្តិសាស្ត្រ និងសមិទ្ធផលនានាដែលសម្រេចបានក្រោយនយោបាយឈ្នះ-ឈ្នះសម្រាប់រៀបចំបញ្ចូលក្នុងកម្មវិធីអប់រំ និងពិព័រណ៍ផ្សេងៗ។ ក្រុមការងារទទួលបន្ទុកស្តូប ឈ្នះ-ឈ្នះ បន្តដំណើរការតាមផែនការមេ និងប្លង់ទីតាំងរួមដូចជាប្លង់ស្ថាបត្យកម្ម ប្លង់រចនាបទសម្ព័ន្ធ ប្លង់សាងសង់ ប្លង់បំពាក់គ្រឿងសម្ភារៈការតុបតែង ត្រូវគ្រប់គ្រងដឹកនាំសាងសង់ទៅតាមលក្ខណៈបច្ចេកទេស និងពេលវេលាបានកំណត់ដោយធានាគុណភាពប្រើប្រាស់យូរអង្វែង សម្រាប់មនុស្សជំនាន់ក្រោយ។ ជាមួយគ្នានេះ សម្តេចពិជ័យសេនាក៏អំពាវនាវដល់លោកឧកញ៉ាលោកលោកស្រីបន្តចូលរួមគាំទ្រថវិកា ឧបករណ៍សម្ភារៈតាមលទ្ធភាពជាក់ស្តែងដើម្បីបង្កលក្ខណៈងាយស្រួលដល់អនុគណៈកម្មការសាងសង់ដំណើរការ ការងារបស់ខ្លួន សម្រេចបានជោគជ័យ៕

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន អញ្ជើញសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារ ស្នាក់ការគណបក្សខេត្តកណ្តាល

*ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុង ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ សមិទ្ធផលនានា និងអគារស្នាក់ការគណបក្សខេត្តកណ្តាល*

នៅព្រឹកថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារគណបក្ស ចុះមូលដ្ឋានខេត្តកណ្តាល តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចតេជោ ហ៊ុន សែន** ប្រធានគណបក្សប្រជាជនកម្ពុជា និងជានាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារនិងសមិទ្ធផលនានា និងអគារស្នាក់ការគណបក្សខេត្តកណ្តាល ដែលមានតម្លៃជាង ៨លានដុល្លារអាមេរិក។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានថ្លែងថា «ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតភាពឈ្លាសវៃ និងប៉ិនប្រសព្វរបស់**សម្តេចតេជោ ហ៊ុន សែន** ក្នុងរយៈពេលជិត ៨ទសវត្សរ៍កន្លងមក កម្ពុជាសម្រេចបាននូវសុខសន្តិភាពពេញលេញបរិបូណ៌ ពង្រឹងបានឆ្លងសាមគ្គីភាពជាតិ រក្សាបានស្ថិរភាពនយោបាយ ជាសមិទ្ធផលដ៏ធំធេងសម្រាប់ប្រទេសជាតិ និងប្រជាជាតិកម្ពុជាទាំងមូល និងជាមូលដ្ឋានមិនអាចខ្វះបានក្នុងការពន្លឿនការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយនិរន្តរភាព។ មិនថាស្ថិតក្នុងកាលៈទេសៈនិងស្ថានភាពបែបណាទេគណបក្សប្រជាជនកម្ពុជា តែងតែប្តេជ្ញាថែរក្សាឱ្យខាងតែបាននូវសុខសន្តិភាពជូនប្រជាពលរដ្ឋកម្ពុជា»។ ទាក់ទិននឹងការអភិវឌ្ឍប្រទេស ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានលើកឡើងថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ នូវក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយជំងឺកូវីដ១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ ក្នុងគោលបំណងស្តារកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលចំពោះមុខ និងរយៈពេលមធ្យមឱ្យត្រឡប់ទៅអត្រាសក្តានុពលប្រកបដោយចីរភាព និងបរិយាប័ន្ធ ក៏ដូចជាការដាក់ចេញនូវគោលនយោបាយជាយុទ្ធសាស្ត្រដើម្បីពង្រឹងភាពធន់សង្គម សេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលវែងដោយឈរលើសសរស្តម្ភចំនួន៣គឺ**ទី១**-ការស្តារឡើងវិញ**ទី២**-ការកែទម្រង់និង**ទី៣**-ការកសាងភាពធន់។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ បានជំរុញដល់សមាជិក សមាជិកាគណបក្សប្រជាជនកម្ពុជាទាំងអស់ ត្រូវធ្វើខ្លួនឱ្យក្លាយទៅជាគំរូល្អក្នុងសង្គម ចេះជួយយកអាសារគ្នា យកចិត្តទុកដាក់ជួយដល់ជនក្រីក្រ ជនមានការលំបាក និងជនដែលស្ថិតនៅក្នុងតម្រូវការ។ ខិតខំរៀនសូត្រសិក្សាស្រាវជ្រាវ ដើម្បីប្រែក្លាយខ្លួនជាបញ្ញាជន ជាធនធានមនុស្សល្អសម្រាប់កម្ពុជា ក្នុងការចូលរួមដឹកនាំ ក៏ដូចជាការចូលរួមជួយអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនទៅមុខជាលំដាប់ប្រកបដោយសុខសន្តិភាព។ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យក៏បានលើកទឹកចិត្តដល់សមាជិកទាំងអស់ បន្តផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឱ្យស្គាល់ពីគុណតម្លៃរបស់គណបក្សដែលបានខិតខំកសាងប្រទេសជាតិពីផេះធ្លាក់ ឱ្យក្លាយជាប្រទេសដែលមានសុខសន្តិភាពពេញលេញមានការរីកចម្រើនជាលំដាប់។

ក្នុងឱកាសនោះ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ក៏បានពាំនាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខ និងក្តីនឹករលឹកដ៏ជ្រាលជ្រៅពីសំណាក់**សម្តេចតេជោ ហ៊ុន សែន** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ជូនចំពោះសមាជិកសមាជិកាគណបក្សគ្រប់រូប ដូចជាប្រជាពលរដ្ឋទាំងអស់ទូទាំងខេត្តកណ្តាលផងដែរ។

អគារគណបក្សប្រជាជនកម្ពុជាខេត្តកណ្តាលថ្មីនេះមានទំហំទទឹង៦០ ម៉ែត្រ និងបណ្តោយ ៨៩,២ម៉ែត្រ កម្ពស់ អតិបរមា ២៣,៥៦ម៉ែត្រ មានផ្ទៃក្រឡាប្រើប្រាស់សរុប ១០.៤៩២ម៉ែត្រការ៉េ សាងសង់នៅលើផ្ទៃដីទំហំ ៣៦.០០០ម៉ែត្រការ៉េ មានជាន់ក្រោមដីជាន់ផ្ទាល់ដី ជាន់ទី១ ជាន់ទី ២ និងជាន់ក្រោមដំបូល។ អគារនេះត្រូវបានរចនាឡើងដោយប្រើប្រាស់នូវរចនាបទជាច្រើនរួមបញ្ចូលគ្នា និងសាងសង់ឡើងបែរមុខទៅទិសខាងកើតជាប់ផ្លូវជាតិលេខ២១ ស្ថិតនៅភូមិទួលក្រសាំង សង្កាត់រកាខ្ពស់ ក្រុងតាខ្មៅ ខេត្តកណ្តាល។ ផ្នែកខាងមុខនៃអគារត្រូវបានលំអដោយរូបចម្លាក់តោថ្មឈរតាមលំនាំរចនាបថអង្គរវត្តចំនួន២ ។ ផ្នែកដំបូលរចនាឡើងដោយប្រើរចនាបទខ្មែរសម័យបុរាណ និងបែងចែកជា៣ ផ្នែក ដោយដំបូលធំ និងចំកណ្តាលនៃអគារ និងត្រូវតភ្ជាប់គ្នាដើម្បីចម្រៀង។ ដំបូលទាំងអស់ត្រូវបានរំលេចដោយហោជាងក្បាច់ភ្ញីអង្គរវត្តមាស ដែលអាចឱ្យមើលឃើញពីគ្រប់ទិសទាំងអស់នៃអគារ។ ទ្វារចូលអគារផ្នែកខាងមុខត្រូវចែកជា៣ ដើម្បីងាយស្រួលក្នុងការប្រើប្រាស់ និងត្រូវបានលំអដោយផ្ទែរ និងសសរពេជ្រ ដោយប្រើប្រាស់នូវរចនាបថបន្ទាយស្រី។ អគារគណបក្សទាំងមូលត្រូវប្រើប្រាស់ថវិកា សម្រាប់សាងសង់ប្រមាណជាង ៨លានដុល្លារអាមេរិក៕

សកម្មភាពសមាជិកវរជ្ជសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស ឹម កា** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្ស-ប្រជាជនកម្ពុជា ប្រធានស្តីទីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរខណ្ឌ និងក្រុមប្រឹក្សាសង្កាត់ទាំង៨ ក្នុងខណ្ឌច្បារអំពៅ ចំនួន ១១១នាក់ នៅសាលាខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត បានជំរុញឱ្យអាជ្ញាធរមូលដ្ឋានខិតខំបម្រើសេវាជូនប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើងថែមទៀត និងត្រូវសហការគ្នា មានសាមគ្គីភាពផ្ទៃក្នុងដើម្បីរួមគ្នាការពារផលប្រយោជន៍និងសុវត្ថិភាពជូនដល់ប្រជាពលរដ្ឋ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ចិន ឈិន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តតាកែវ បានអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តតាកែវ ។

ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឃឹម តែលី** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តកំពង់ចាម និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍវិស័យកសិកម្ម និងជនបទ អញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តកំពង់ចាម នៅសាលសន្និសីទសាលាខេត្តកំពង់ចាម។

ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកណ្តាល បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសសេចក្តីសម្រេចបញ្ចូលសមាជិកបក្សថ្មីគណបក្សប្រជាជនកម្ពុជាចំនួន ៤០០នាក់ស្ថិតនៅភូមិភូមិធំ ឃុំភូមិធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជា ចាន់តូ** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តកំពង់ធំបានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់សាលាធម្មសភា ចេតិយ កុដិ និងសមិទ្ធផលនានាក្នុងវត្តសន្ទុកក្រៅ ស្រុកសន្ទុក ខេត្តកំពង់ធំ ។ ឯកឧត្តមបានថ្លែងថា គណបក្សប្រជាជនកម្ពុជា គឺជាស្ថាបនិកសន្តិភាព ឯកភាពជាតិ ដែលធ្វើឲ្យមានការអភិវឌ្ឍប្រទេសគ្រប់ហេដ្ឋារចនាសម្ព័ន្ធ គ្រប់ផ្នែក គ្រប់វិស័យ។

ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិតសភាចារ្យ **អ៊ុក រ៉ាប៊ុន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង បានអញ្ជើញជាអធិបតីក្នុងពិធីជួបសំណេះសំណាល ពិភាក្សា និងត្រួតពិនិត្យ សភាពការណ៍ការងារទូទៅជាមួយក្រុមប្រឹក្សា និងសមាជិក ក្រុង សង្កាត់ទូទាំងក្រុងកំពង់ឆ្នាំង នៅសាលាក្រុងកំពង់ឆ្នាំង។

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **គន់ គីម** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះជួយខេត្តឧត្តរមានជ័យ បានអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបការងារឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំថ្មី ឆ្នាំ២០២២ នៅរដ្ឋបាលខេត្តឧត្តរមានជ័យ។ ឯកឧត្តមថ្លែងថា ការងារបម្រើជាប្រយោជន៍សម្រាប់ជាតិ ការងារលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ ការងារផ្តល់សេវា និងការងារដោះស្រាយការលំបាកជូនប្រជាពលរដ្ឋ គឺជាការងារអាទិភាពខ្ពស់របស់ប្រតិបត្តិការទាំងឡាយរបស់ជាតិ ដោយមិនអាចរអ៊ូរទាំថានឿយហត់ ឬនឿយណាយនោះឡើយ។

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **មាស សុភា** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះវិហារ បានអញ្ជើញជាអធិបតីក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅការងារឆ្នាំ២០២២ របស់រដ្ឋបាលខេត្តព្រះវិហារ ។ ឯកឧត្តមបានវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំខេត្ត និងក្រុមការងាររាជរដ្ឋាភិបាលចុះជួយមូលដ្ឋានគ្រប់លំដាប់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងរួមគ្នាយ៉ាងសកម្មក្នុងការបំពេញតួនាទីភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេចបាននូវសមិទ្ធផលថ្មីៗ។

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានយុវជនគណបក្សថ្នាក់កណ្តាល បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសសមាសភាពក្រុមការងារយុវជនគណបក្សខេត្តកំពង់ស្ពឺ។ ឯកឧត្តមបណ្ឌិតថ្លែងថា យុវជនជាឆ្អឹងខ្នងដ៏រឹងមាំរបស់សង្គមជាតិ និងជាកម្លាំងបន្តវេនដ៏មុតស្រួច ក្នុងការដឹកនាំប្រទេសឆ្ពោះទៅរកវឌ្ឍនភាពជឿនលឿនរុងរឿង។ យុវជនត្រូវខិតខំប្រឹងប្រែងយកចិត្តទុកដាក់ពង្រឹង និងពង្រីកសក្តានុពលរបស់ខ្លួនឱ្យកាន់តែរឹងមាំច្បាស់លាស់ទាំងផ្នែកសមត្ថភាព ចំណេះដឹង ជំនាញ និងផ្នែកចរិយាសម្បត្តិប្រកបដោយគុណធម៌ សីលធម៌ រួមជាមួយនឹងស្មារតី និងសកម្មភាពចូលរួមថែរក្សានូវសមិទ្ធផលដែលមានស្រាប់ឱ្យបានគង់វង្ស និងបន្តពង្រីកបន្ថែមទៀតនូវសមិទ្ធផលវិជ្ជមានថ្មីៗ សម្រាប់ជាប្រយោជន៍ជាតិ មាតុភូមិ និងប្រជាជន។

សកម្មភាពសមាជិករដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **ចម ប្រសិទ្ធ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានខេត្តកែប បានអញ្ជើញផ្តល់រង្វាន់ម៉ូតូម៉ាក់ Honda Dream សេរីឆ្នាំ២០២២ ម្នាក់មួយគ្រឿងដល់សិស្សប្រឡងជាប់ជ័យលាភីនិទ្ទេស A ទាំង ៣រូប និងសិស្សប្រឡងជាប់ និទ្ទេសB ១១នាក់ ទទួលបាន កុំព្យូទ័រLaptop ម្នាក់មួយគ្រឿង និងផ្តល់ជូនថវិកាជូនលោកគ្រូអ្នកគ្រូក្នុងម្នាក់១០០ដុល្លារអាមេរិកផងដែរ នៅក្នុងខេត្តកែប។

ថ្ងៃទី២៧ខែមីនាឆ្នាំ២០២២ឯកឧត្តម **ខៀវ កាញារីទ្ធ** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងជាប្រធានក្រុមការងារគណបក្សចុះជួយស្រុកកោះសូទិន ខេត្តកំពង់ចាម រួមជាមួយ ឯកឧត្តម **អ៊ុន ចាន់ដា** សមាជិកគណៈកម្មាធិការកណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សប្រជាជនកម្ពុជា ខេត្តកំពង់ចាម បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ អគារទីស្នាក់ការគណបក្សប្រជាជនកម្ពុជា ឃុំព្រៃតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម។

ក្នុងអំឡុងពេលថ្មីៗនេះ ឯកឧត្តម **ង្រុំ សុខា** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និងជាប្រធានក្រុមការងារខេត្តក្រចេះបានថ្លែងក្នុងពិធីជួបសំណេះសំណាល និងលើកទឹកចិត្តដល់សិស្សានុសិស្សក្នុងខេត្តក្រចេះ ដែលបានប្រឡងជាប់និទ្ទេស A ចំនួន ៤៥នាក់ និងនិទ្ទេស B ចំនួន ១៣០នាក់ ក្នុងសម័យប្រឡងមធ្យមសិក្សាទុតិយភូមិថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១ កន្លងទៅនេះថា៖ មោទនភាពដែលក្មួយៗសំរេចបានគឺជាការណីកិច្ចក្នុងនាមជាសិស្សានុសិស្ស ចំពោះមាតិបិតានិងគ្រួសារ ចំពោះលោកគ្រូ អ្នកគ្រូ សាលារៀន និងសហគមន៍ ក៏ដូចជាចំពោះសង្គមជាតិទាំងមូល។ ក្រុមការងារបានប្រកាសផ្តល់ជូនអាហារូបករណ៍១០០ភាគរយ ដល់ជ័យលាភី និទ្ទេស A និង និទ្ទេស B ទាំងអស់ សំរាប់ការសិក្សាថ្នាក់ឧត្តមសិក្សាបន្តទៀត ទៅតាមការជ្រើសរើសរបស់សាមីខ្លួន។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ប៉ា សុជាតិវង្ស** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា បានអញ្ជើញជួបសំណេះសំណាលជាមួយបេក្ខភាពក្រុមប្រឹក្សាសង្កាត់ និងគណៈសាខាបក្សភូមិទាំង៨ ក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ ដើម្បីចាត់តាំងអនុវត្តផែនការសកម្មភាពឆ្ពោះទៅកាន់ការបោះឆ្នោតនាថ្ងៃទី ៥ មិថុនា ឆ្នាំ២០២២ ខាងមុខនេះ ។

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **ម៉ម ប៊ុនឆាង** សមាជិកគណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អនុប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត និងទទួលជួយស្រុកកណ្តាលស្ទឹងខេត្តកណ្តាល ប្រធានគណៈកម្មការទី១០ និងជាអ្នកនាំពាក្យព្រឹទ្ធសភា បានអញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះ សំណាលជាមួយថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា នៅមូលដ្ឋានឃុំគោកគ្រប់ ចំនួន ១១៥នាក់ និងបានឧបត្ថម្ភសមាជិកនៃអង្គពិធីម្នាក់ៗថវិកា ៣០.០០០រៀល ស្ថិតនៅឃុំគោកគ្រប់ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល។

សកម្មភាពសមាជិកវដ្ឋសភា-ព្រឹទ្ធសភា-រាជរដ្ឋាភិបាល និងមន្ត្រីគណបក្ស

ថ្ងៃទី ១៣ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ស្សោង សាវ៉ាត** សមាជិកគណៈ-កម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា ប្រធានគណៈកម្មាធិការគណបក្ស ខេត្តព្រៃវែង អមដំណើរដោយ ឯកឧត្តម **ហ៊ុឺ បាវី** ប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានស្រុកព្រះស្តេច និងសហការីបានអញ្ជើញជាអធិបតីក្នុងពិធីក្រុងពាលីបញ្ចុះបឋមសិលាសាងសង់ទីស្នាក់ការគណបក្សឃុំ អង្គរអង្គ ស្រុកពាមជរ ខេត្តព្រៃវែង។ បន្ទាប់មកឯកឧត្តមក៏បានអញ្ជើញចូលរួមដង្ហែរបុណ្យផ្តាសាមគ្គីដើម្បីប្រមូលបច្ច័យកសាងព្រះវិហារ ក្នុងវត្តក្តាមពុក ឃុំសេនាវាជឧត្តម ស្រុកព្រះស្តេច ខេត្តព្រៃវែង ដោយក្នុងនោះ ឯកឧត្តម **ស្សោង សាវ៉ាត** បានចូលបុណ្យនូវស៊ីម៉ង់ត៍ ១០ តោន , ឯកឧត្តម **ហ៊ុឺ បាវី** ចូលបច្ច័យចំនួន ២០ លានរៀល និងលោក **ភុន សម្ផស្ស** អនុប្រធានគណបក្សស្រុកក៏បានចូលរួមឧបត្ថម្ភខ្សាច់ចំនួន២ឡានផងដែរ ។

ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **ចាយ មូរិន** សមាជិកគណៈ កម្មាធិការ-កណ្តាល គណបក្សប្រជាជនកម្ពុជា អ្នកតំណាងរាស្ត្រមណ្ឌលខេត្តត្បូងឃ្មុំ តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមបណ្ឌិត **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍គណបក្ស ប្រជាជនកម្ពុជា និងជាប្រធានយុវជនគណបក្សថ្នាក់កណ្តាល បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានាស្ថិតក្នុងវត្តតេជសុវណ្ណភូមិ នៅក្នុងភូមិនិគមលើ ឃុំស្រឡប់ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ ។ សមិទ្ធផលទាំងនោះរួមមាន ៖ផ្លូវ១ខ្សែ ប្រវែង៨០០ម៉ែត្រ សាឡុំមួយខ្នង សាលាបុណ្យមួយខ្នង កុដិ២ខ្នងមាន៧បន្ទប់ បង្គោលភ្លើងធំៗចំនួន៧ដើម ដងទង់ជាតិចំនួន៣០ដើមអណ្តូងទឹក១បន្ទប់អនាម័យ ៨បន្ទប់ និងសាលារៀនមួយខ្នងមាន៣បន្ទប់។

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជាម ប៉ែអា** អ្នកតំណាងរាស្ត្រ ខេត្តព្រៃវែង និងជាសមាជិកគណៈកម្មការទី៥ នៃរដ្ឋសភា បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធសមិទ្ធផលនានានៅវត្តសានគ ស្ថិតនៅភូមិសានគរ "ក" ឃុំសានគរ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមានប្រជាពលរដ្ឋចូលរួមសរុប ៤០០នាក់ ។ ឯកឧត្តមថ្លែងថា វត្តសានគរនេះជាសម្បត្តិវប្បធម៌ដ៏ថ្លៃថ្លាសម្រាប់កូនចៅជំនាន់ក្រោយ។បងប្អូនរស់នៅទីនេះមានជីវភាពធូធារ នៅឃុំនេះមានត្រាក់ទ័រ២៩៨គ្រឿង ឡានតូចធំ ២៥៣គ្រឿង និងម៉ូតូប្រមាណ ៨.០០០គ្រឿង ក្នុងចំនួនប្រជាជនសរុប១៩.០០០នាក់។ សមិទ្ធផលទាំងនេះដោយសារប្រទេសមានសន្តិភាពក្រោមនយោបាយឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។

ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ហ៉ៅ ធនិន** សមាជិកគណៈ-កម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជាអភិបាលនៃគណៈអភិបាលខេត្តកំពត បានអញ្ជើញផ្តល់ស្បៀងជូនប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតក្នុងបរិវេណសាលាខេត្តកំពតក្នុងមួយគ្រួសារៗទទួលបានអង្ករចំនួន១០គីឡូក្រាម សរុបចំនួនប្រមាណ៦៨១គ្រួសារ។

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២ លោកជំទាវ **មិថុនា ភូថង** សមាជិកាគណៈ-កម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា អភិបាលនៃគណៈអភិបាល ខេត្តកោះកុង បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាល ជាមួយស្ត្រីជាគ្រូបង្រៀនគ្រូពេទ្យ និងនិស្សិត ដើម្បីអបអរសាទរ ខួបលើកទី ១១១ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២២ ក្រោមមូលបទ **"សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត"**។ លោកជំទាវ អភិបាលខេត្ត បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះប្រធានគណៈកម្មការសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ខេត្តកោះកុង និងជាសមាជិកក្រុមប្រឹក្សាខេត្ត និងក្រុមការងារទាំងអស់ដែលបានយកចិត្ត ទុកដាក់ជួយបង្កលក្ខណៈ និងគាំទ្រគ្រប់បែបយ៉ាងដល់គណៈកម្មការសាខាសមាគមនារីខេត្ត ឱ្យអាចដំណើរការសកម្មភាពរបស់ខ្លួនបានយ៉ាងរលូន។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិក-គណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសសមាសភាពក្រុមការងារយុវជនគណបក្សប្រជាជនខេត្តកណ្តាល ។ ឯកឧត្តម **គង់ សោភ័ណ្ឌ** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកណ្តាល ព្រមទាំងថ្នាក់ដឹកនាំយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងថ្នាក់ដឹកនាំ សមាជិក សមាជិកា ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្ត សរុបចំនួន ៦៤១រូប ក៏បានអញ្ជើញចូលរួមផងដែរ ។

ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ជុន ថៅវ៉ាត** សមាជិក-គណៈកម្មាធិការកណ្តាល ប្រធានផ្នែកក្រសួង-ស្ថាប័ន នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានជនបង្គោលយុវជនថ្នាក់កណ្តាលចុះជួយស្រុកព្រៃឈរ ខេត្តកំពង់ចាម តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ហ៊ុន ម៉ាណែត** អញ្ជើញជួបសំណេះសំណាលបំពាក់បំប៉ននយោបាយសតិអារម្មណ៍ និងណែនាំអំពីតួនាទីភារកិច្ចដល់យុវជនគណបក្សប្រជាជនកម្ពុជាចំនួន ២៥៦នាក់ ក្នុងឃុំចំនួន៥ (វគ្គទី២) ក្នុងចំណោមឃុំទាំង១៥ នៃស្រុកព្រៃឈរ ដើម្បីឆ្លោះទៅយកជ័យជម្នះនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ២០២២ ខាងមុខ នៅទីស្នាក់ការគណបក្សស្រុកព្រៃឈរ ខេត្តកំពង់ចាម។



ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **យស ផានិត្តា** សមាជិក-គណៈកម្មាធិការកណ្តាល និងជាប្រធានផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានអញ្ជើញដឹកនាំកិច្ចប្រជុំតាមដានវឌ្ឍនភាពការងាររបស់ផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ដែលមានការអញ្ជើញចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អនុប្រធាន សមាជិក សមាជិកា និងមានឯកឧត្តម លោកជំទាវ ក្រុមគ្រូឧទ្ទេស-គ្រូជំនួយ ព្រមទាំងក្រុមចំណុះទាំង៣ ផ្នែកបណ្តុះបណ្តាល នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល សរុបចំនួន ២៩រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២២ ឯកឧត្តម **ហោ សួរ** សមាជិកគណៈ-កម្មាធិការកណ្តាល និងជាប្រធានផ្នែករាជធានី ខេត្ត នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារជនបង្គោលយុវជនស្រុកបាធាយ ខេត្តកំពង់ចាម តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវ បាននាំយកម៉ាស់ចំនួន ៤០.០០០សន្លឹក និងថ្នាំចិនចំនួន ៨០០ប្រអប់ ប្រគល់ជូនក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាស្រុកបាធាយ ខេត្តកំពង់ចាម។



ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ម៉ែ ពោធិ៍ណា** សមាជិកគណៈ-កម្មាធិការកណ្តាល និងជាប្រធានផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំប្រចាំខែរបស់ផ្នែកព័ត៌មាន និងបណ្តាញផ្សព្វផ្សាយសង្គម អំពីវឌ្ឍនភាពការងារដែលបាននឹងកំពុងអនុវត្ត និងទិសដៅការងារក្នុងខែបន្ទាប់សម្រាប់ឆ្នាំ២០២២ ដែលមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក សមាជិកា ផ្នែក និងក្រុមជំនួយការផ្នែក តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឆាយ វណ្ណា** ប្រធានផ្នែកវប្បធម៌ និងសាសនា នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានដឹកនាំកិច្ចប្រជុំប្រចាំខែ ស្តីពីអំពីវឌ្ឍនភាពការងារដែលបាននឹងកំពុងអនុវត្ត និងទិសដៅការងារក្នុងខែបន្ទាប់សម្រាប់ឆ្នាំ២០២២ របស់ផ្នែកវប្បធម៌ និងសាសនា នៃយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល ដែលមានការចូលរួមពីឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាសមាជិក សមាជិកា ផ្នែកនិងក្រុមជំនួយការផ្នែក សរុបចំនួន ៣៣រូប តាមរយៈប្រព័ន្ធបញ្ជូនរូបភាព និងសំឡេងដោយផ្ទាល់(Zoom Meeting)។

សកម្មភាពរបស់ក្រុមការងារយុវជនគណបក្ស

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ហ៊ុន ម៉ាណែត** សមាជិកគណៈអចិន្ត្រៃយ៍នៃគណៈកម្មាធិការកណ្តាល និងជាប្រធានយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ក្នុងពិធីប្រកាសសមាសភាពក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ស្ពឺ ដែលដឹកនាំដោយ ឯកឧត្តម **ខ្ញី សំណាង** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ស្ពឺ ព្រមទាំងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងថ្នាក់ដឹកនាំ សមាជិក សមាជិកា ក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្ត សរុបចំនួន ៤៥៣រូប នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ស្ពឺ។

ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២២ លោក **ស្រី សុភ័ក្ត្រ** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សខេត្តកំពង់ចាម និងថ្នាក់ដឹកនាំក្រុមការងារយុវជនគណបក្សខេត្ត បានអញ្ជើញចូលរួមជាមួយគណបក្ស រៀបចំវគ្គបណ្តុះបណ្តាល និង ធ្វើបទឧទ្ទេសនាមមេរៀន ស្តីពីច្បាប់ បទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់ជូនដល់ក្រុមប្រឹក្សាអ្នកច្បាប់គណបក្សក្រុងស្រុកប្រធានគណបក្សមន្ទីរអង្គភាពក្រុមការងារយុវជនគណបក្សខេត្ត និងក្រុងស្រុកក្រោមអធិបតីភាព ឯកឧត្តម **ខ្លូត ធន** អនុប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **អ៊ុន ចាន់ដា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានគណៈកម្មាធិការគណបក្សខេត្តកំពង់ចាម ដែលមានអ្នកចូលរួមចំនួន ១៨៤រូប នៅមន្ទីរគណបក្សប្រជាជនកម្ពុជាខេត្តកំពង់ចាម។

ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **តុន សារពេជ្រ** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាខេត្តកំពត ព្រមទាំងថ្នាក់ដឹកនាំក្រុមការងារយុវជនគណបក្សខេត្តកំពត បានអញ្ជើញចុះសួរសុខទុក្ខលោកគ្រូ អ្នកគ្រូពេទ្យតាមមណ្ឌលសុខភាពក្នុងមូលដ្ឋានឃុំ ភូមិ នៃស្រុកបន្ទាយមាស ដែលកំពុងចុះចាក់វ៉ាក់សាំងជូនបងប្អូនប្រជាពលរដ្ឋនៅតាមភូមិ និងតាមមណ្ឌល ព្រមទាំងបាននាំយកនូវគ្រឿងឧបភោគបរិភោគសម្ភារៈមួយចំនួន ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តមបណ្ឌិត **ម៉ៅ ធនិន** មកផ្តល់ជូនដល់ក្រុមគ្រូពេទ្យទាំង៥មណ្ឌល នៅស្រុកបន្ទាយមាស ខេត្តកំពត។

ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **សុិន ឌុច្ឆី** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងធនធានទឹកនិងឧតុនិយមព្រមទាំងក្រុមការងារបាននាំយកអំណោយដ៏ថ្លៃថ្លារបស់ ឯកឧត្តម **ហ៊ុន ម៉ាណែត** និងលោកជំទាវ ប្រគេនព្រះសង្ឃគង់នៅវត្តអង្គសិរី និងចែកជូនប្រជាពលរដ្ឋក្រីក្រ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ នៃវិទ្យាល័យ ហ៊ុន សែន ព្រះធម្មស្រះ អនុវិទ្យាល័យ ត្រពាំងរកា សាលាបឋមសិក្សាអរិយកស្សប និងសាលាបឋមសិក្សាអង្គសិរី ស្ថិតនៅក្នុងឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល។

ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **អ៊ុក ប្រុសា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានកិត្តិយសក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងពាណិជ្ជកម្ម ឯកឧត្តម **វង ង៉ា** សមាជិកយុវជនគណបក្សប្រជាជនកម្ពុជាថ្នាក់កណ្តាល និងជាប្រធានក្រុមការងារយុវជនគណបក្សប្រជាជនកម្ពុជាក្រសួងពាណិជ្ជកម្ម បានអញ្ជើញជួបសំណេះសំណាលជាមួយមន្ត្រីគណបក្សភូមិ ឃុំ និងបេក្ខជនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ ដើម្បីផ្សព្វផ្សាយពីទិសដៅភារកិច្ចឆ្ពោះទៅកាន់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៦ នៅខែមិថុនា ឆ្នាំ២០២២ នៅឃុំត្រពាំងព្រះ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ចំនួន៧២រូប។

ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២២ ឯកឧត្តម **ឈឹម ឃិនដារ៉ែត** សមាជិកយុវជនគណបក្សប្រជាជន ប្រធានក្រុមការងារយុវជនគណៈកម្មាធិការគណបក្សអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានឃុំភារីមានជ័យ ឯកឧត្តម **រស់ សីលវ៉ាត់** ឯកឧត្តម **ឌី ចាន់ប៊ុនលឿ** និងឯកឧត្តម **ឈា សិទ្ធិ** សមាជិកអចិន្ត្រៃយ៍ក្រុមការងារយុវជន និងជាអនុប្រធានក្រុមការងារគណបក្សចុះមូលដ្ឋានឃុំភារីមានជ័យ ស្រុកបសេដ្ឋ បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំសំណេះសំណាលជាមួយក្រុមការងារចល័តបោះឆ្នោតឃុំ ដែលរួមមានគណៈកម្មាធិការគណបក្សស្រុក គណៈកម្មាធិការគណបក្សឃុំ សាខាគណបក្សភូមិ និងយុវជនគណបក្សឃុំ នៅទីស្នាក់ការគណបក្សប្រជាជនកម្ពុជាឃុំភារីមានជ័យ ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ។

សមិទ្ធផលមួយចំនួននៃវិស័យសេដ្ឋកិច្ច

❋ អគ្គនាយកដ្ឋានពន្ធដារ ប្រមូលចំណូលពន្ធអាករជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញបានចំនួន ១១.២៦៦,៧៩ ប៊ីលានរៀល (ប្រមាណជា ២.៧៨១,៩២លានដុល្លារអាមេរិក) ធៀបនឹងផែនការច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២១ ដែលតម្រូវប្រមូលចំណូលឲ្យបានចំនួន ៩.០៨៤,៤២ ប៊ីលានរៀល (ប្រមាណ ២.២៤៣,០៧លានដុល្លារអាមេរិក) ស្មើនឹង ១២៤,០២% នៃផែនការប្រចាំឆ្នាំ ដោយលើសផែនការចំនួន ២៤,០២% ស្មើនឹង ២.១៨២,៣៧ ប៊ីលានរៀល (៥៣៨,៨៥លានដុល្លារអាមេរិក) ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ ២០២០មានការថយចុះ ចំនួន ៤៣៣,៧៥ ប៊ីលានរៀល (ប្រមាណ១០៧.០៩ លានដុល្លារអាមេរិក) ស្មើនឹង ៣,៧១% ។

❋ ទំហំពាណិជ្ជកម្មរបស់កម្ពុជាសម្រេចបានទឹកប្រាក់ចំនួន៣៧.៣៤៦ លានដុល្លារអាមេរិកកើនឡើង២៨%ក្នុងនោះការនាំចេញមានទឹកប្រាក់ ១៤.២៨៦ លានដុល្លារអាមេរិក ថយចុះ ២% និងការនាំចូលមានទឹកប្រាក់២៣.០៦០លានដុល្លារអាមេរិកកើនឡើង ៥៨%បើធៀបនឹងឆ្នាំមុន ។ ក្រសួងបានផ្តល់អាជ្ញាបណ្ណនាំចេញ ៥១ ច្បាប់ គិតជាទឹកប្រាក់ប្រមាណ ៦ លានដុល្លារអាមេរិក និងផ្តល់អាជ្ញាបណ្ណនាំចូល ៩ ច្បាប់ គិតជាទឹកប្រាក់ប្រមាណ១ លានដុល្លារអាមេរិក ។ ការផ្តល់លិខិតបញ្ជាក់ការនាំចេញ នាំចូល ត្បូងពេជ្រមិនទាន់កែច្នៃ និងសល់ពីការកែច្នៃសរុបចំនួន៣៦ច្បាប់គិតជាទឹកប្រាក់ចំនួន២៤លានដុល្លារអាមេរិក ក្នុងនោះការនាំចូល ១៥ ច្បាប់ គិតជាទឹកប្រាក់ចំនួន ១៥ លានដុល្លារអាមេរិក និងនាំចេញ២១ ច្បាប់ គិតជាទឹកប្រាក់ ៩ លានដុល្លារអាមេរិក។

❋ កម្ពុជាបានទទួលចំណូលពីការនាំចេញកសិផល (ឯកតាតម្លៃផ្អែកតាមវិក្កយបត្ររបស់អ្នកនាំចេញ) ក្នុងរយៈពេល ១២ ខែ បានប្រមាណ ៤.៣២៣.៧១៩.៣០០,៥៨ ដុល្លារអាមេរិក ក្នុងនោះការនាំចេញអង្ករបានចំនួន ៥២៧.៥៩៣.៩៩៥ ដុល្លារអាមេរិក ការនាំចេញស្រូវបានចំនួន ៦៣១.៤០៧.៨២២ ដុល្លារអាមេរិក និងនាំចេញកសិផលក្រៅពីស្រូវ អង្ករ បានចំនួន ៣.១៦៤. ៧១៧.៤៨៣,៥៨ ដុល្លារអាមេរិក ។

❋ នាំចេញស្រូវអង្ករមានបរិមាណសរុបចំនួន៤.១៤៤.៤៨៧ តោន ក្នុងនោះការនាំចេញអង្ករមានបរិមានសរុប ៦១៧.០៦៩ តោន ថយចុះ ៧៣.៧៦០ តោនធៀបនឹងឆ្នាំមុនដែលមានចំនួន ៦៩០. ៨២៩ តោន ស្មើនឹង ១០,៦៨% ។ ការនាំស្រូវមានបរិមាណសរុប៣.៥២៧.៤១៨ តោន កើនឡើងចំនួន ១.៣៣៨.៦១៤ តោន ធៀបនឹងឆ្នាំមុនមានចំនួន ២.១៨៨.៨០៤ តោន ស្មើនឹង ៦១,១៦%។

❋ នាំចេញកសិផលក្រៅពីស្រូវអង្ករមានចំនួន ៥.១៨០.០០៥,៨១ តោន កើនឡើងចំនួន ១.៦៨៣. ១៩៨,៧១ តោន ធៀបនឹងឆ្នាំមុនមានចំនួន៣.៤៩៦.៨០៧,១០ តោនស្មើនឹង ៤៨,១៤%។

❋ នាំចេញកៅស៊ូមានចំនួន ៣១២.៨១២ តោន ធៀបនឹងឆ្នាំមុនកើនឡើង ២៦.៩៥៥ តោនស្មើនឹង ៩% និងឈើកៅស៊ូ ៥.៨៣៨ម៣ ។ ផ្ទៃដីចម្ការកៅស៊ូរដ្ឋ និងឯកជនមានផ្ទៃដីសរុបចំនួន ៤០៤.១៦០ ហ.ត ក្នុងនោះផ្ទៃចម្ការកៅស៊ូ កសិ-ឧស្សាហកម្មចំនួន ៤៨.៥៤៦ ហ.ត ផ្ទៃដីចម្ការកៅស៊ូសម្បទានដីសេដ្ឋកិច្ច មានចំនួន ១៩៤.៤៥៤ ហ.ត និងផ្ទៃដីចម្ការកៅស៊ូគ្រួសារ មានចំនួន ១៦១.១៦០ ហ.ត ។ ផ្ទៃដីជៀរដំរកៅស៊ូ ៣១៤.៣១៩ ហ.ត ស្មើនឹង ៧៨% និងផ្ទៃដីថែទាំ ៨៩.៨៤១ ហ.ត ស្មើនឹង ២២% ។ ផលិតផលជំរកៅស៊ូមានចំនួន ៣១៩.៥០៩តោន កើនឡើង ២៨.១៩១ តោន ស្មើនឹង ១០% បើធៀបនឹងឆ្នាំមុន និងផលិតផលឈើកៅស៊ូបានចំនួន ៦.០៤៨ម៣ ។

❋ការនាំចេញផលនេសាទសរុបមានចំនួន៣.០៦៦តោនក្នុងនោះផលនេសាទស្រស់មានចំនួន ២.៩១៦ តោន ស្មើនឹង ៣៦,៤៥% នៃផែនការ ៨.០០០ តោន ធៀបនឹងឆ្នាំមុនកើនឡើង ៩៧១ តោន និងផលនេសាទកែច្នៃមានចំនួន ១៥០ តោន ស្មើនឹង ៧,៥០% នៃផែនការ ២.០០០ តោន ធៀបនឹងឆ្នាំមុនថយចុះ ៨៤ តោន ។ វិស័យជលផលសរុបបានចំនួន ៥៨១.៧១២.៩៧៦រៀលស្មើនឹង ១៦២,២២% នៃផែនការ ៣៥៨.៦០០.០០០រៀល បើធៀបនឹងឆ្នាំមុនថយចុះចំនួន ៩៧៨.០៧២.៧៨៤រៀលនិងថ្លៃសួយសារផលអនុផលព្រៃឈើសរុប ៦.៨៨៤.៤៦៨.៤១៧រៀលនិង២.៦០៨.៩៩៣,៧២ដុល្លារអាមេរិក។

❋ នាំចេញទំនិញទៅក្រៅប្រទេសមានតម្លៃសរុបប្រមាណ ៧២.០៣៧,៤៤ប៊ីលានរៀល ស្មើនឹងប្រមាណ ១៧.៥៧៤,៣៩លានដុល្លារអាមេរិកកើនឡើង ២,១៤% បើធៀបនឹងឆ្នាំមុន និងការនាំចូលមកវិញមានតម្លៃប្រមាណ ១១៣.៦៤០,៥៧ ប៊ីលានរៀល ស្មើនឹងប្រមាណ ២៧.៧២៣,៩៤លានដុល្លារអាមេរិកកើនឡើង ៤៨,០៨% បើប្រៀបធៀបនឹងឆ្នាំមុន ។

- ការងារបង្កបង្កើនផល

ក. ល្បឿននៃការបង្កបង្កើនផលស្រូវរដូវប្រាំង

លទ្ធផលនៃការភ្ជួររាស់រៀបចំដីសម្រេចបានចំនួន ៦៤៩.៥៦៦ ហ.ត ក្នុងនោះភ្ជួរដោយគោ ក្របី មានចំនួន ៤.២៥៧ ហ.ត ស្មើនឹង ០,៦៦% និងដោយប្រើប្រាស់គ្រឿងយន្តចំនួន ៦៤៥.៣០៩ ហ.ត ស្មើនឹង ៩៩,៣៤%។ ផ្ទៃដីសាបសម្រេចបានចំនួន ២៦ហ.ត។ លទ្ធផលស្មូងនិងព្រោះសម្រេចបានចំនួន ៦៤៩.៥៣០ ហ.ត ស្មើនឹង១៤១,៤៥% នៃផែនការ៤៥៩.២០០ហ.ត លើសឆ្នាំមុន ៣៣.៣៧៥ ហ.ត ។ ល្បឿននៃការប្រមូលផលសម្រេចបានចំនួន ៦៤៦.៥៣០ ហ.ត ដោយទទួលបានបរិមាណស្រូវសរុបចំនួន២.៩៣១.៨៤២ តោន និងទទួលបានទិន្នផលគិតជាមធ្យម ៤,៥៣៥ តោន/ហ.ត។

ខ.ល្បឿននៃការបង្កបង្កើនផលស្រូវរដូវវស្សា

លទ្ធផលនៃការភ្ជួររាស់រៀបចំដីសម្រេចបានចំនួន២.៩២៥.៨២៨ ហ.ត ក្នុងនោះភ្ជួរដោយគោ ក្របី មានចំនួន ១៦.៦២៤ ហ.ត ស្មើនឹង ០,៥៧% និងដោយគ្រឿងយន្តចំនួន ២.៩០៩.២០៤ ហ.ត ស្មើនឹង ៩៩,៤៣% ។ ផ្ទៃដីសាបសរុបបាន ១២.៣៩២ ហ.ត តិចជាងឆ្នាំមុន ៣.៤០១ ហ.ត ។ លទ្ធផលស្ទូង និងព្រោះសម្រេចបានចំនួន ២.៩០១.៦០៥ហ.តស្មើនឹង១១១,២១%នៃផែនការ ២.៦០៩.០៦៥ហ.ត លើសឆ្នាំមុន ៩៤.៩៨២ ហ.ត។ ល្បឿននៃការប្រមូលផលស្រូវស្រាលសម្រេចបានចំនួន ២.៨៧២.៩៤៨ ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៩.០៦០.៤៩៥ តោន លើសឆ្នាំមុន ៨៤០.៨១៨ តោន និងទទួលបានទិន្នផលគិតជាមធ្យម ៣,២៥៦ តោន/ហ.ត ។

គ. ល្បឿននៃការបង្កបង្កើនផលដំណាំសាកវប្បកម្ម និងដំណាំឧស្សាហកម្មរដូវប្រាំង

ដំណាំសាកវប្បកម្មអនុវត្តបានសរុប ២០.០៣៣ ហ.ត ស្មើនឹង ៥៦,០២% នៃផែនការ ៣៥.៧៦០ ហ.ត តិចជាងឆ្នាំមុន ៤.២១៦ ហ.ត ។ ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ៤៨.១៩៦ ហ.ត ស្មើនឹង ៥៣,៦៦% នៃផែនការ ៨៩.៨១០ហ.ត តិចជាងឆ្នាំមុន ៥.១៧៦ ហ.ត ។

❋ ទិន្នន័យផ្គត់ផ្គង់អគ្គិសនីមានចំនួន ១២.៣៦៥,៨៧ជីហ្គាវ៉ាត់ម៉ោង ក្នុងនោះ ការផ្គត់ផ្គង់នៅក្នុងស្រុកមានចំនួន ៨.៤១២,៥៩ ជីហ្គាវ៉ាត់ម៉ោង ដោយមានប្រភពពីការដុតធ្យូងថ្មមានចំនួន ៣.២៩៨,៤៣ ជីហ្គាវ៉ាត់ម៉ោង, វារីអគ្គីសនីមានចំនួន ៤.៩៦៨,៨០ជីហ្គាវ៉ាត់ម៉ោង, ដុតប្រេងមានចំនួន ៥២៥,៤៣ជីហ្គាវ៉ាត់ម៉ោង និងថាមពលកកើតឡើងវិញ មានចំនួន ៦១៩,៩៣ជីហ្គាវ៉ាត់ម៉ោង និងការផ្គត់ផ្គង់ដោយនាំចូលមានចំនួន ២.៩៥៣,២៨ជីហ្គាវ៉ាត់ម៉ោង ដោយមានប្រភពពីប្រទេសវៀតណាម មានចំនួន ៥៤៥,៩២ជីហ្គាវ៉ាត់ម៉ោង, ប្រទេសឡាវមានចំនួន ២.១៩២ ជីហ្គាវ៉ាត់ម៉ោង និងប្រទេសថៃមានចំនួន ២១៥,៣៦ជីហ្គាវ៉ាត់ម៉ោង។

❋ រោងចក្របង្កើតថ្មីមានចំនួន ១៦៣ បើធៀបនឹងឆ្នាំមុន ២៣៥

ចំយុះ ៧២ ស្មើនឹង ៣០,៦៣%។គិតត្រឹមដំណាច់ឆ្នាំ ២០២១ នេះ រោងចក្រដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ មានចំនួន ១.៨៧៩ និងមានពលករបម្រើការងារមានចំនួន ៩៨៦.៦៧៧ នាក់ ក្នុងនោះផ្នែកឧស្សាហកម្មតម្បាញ កាត់ដេរ ចាក់ស្បែកជើង និងកាបូបមានចំនួន ១.០៨៦ រោងចក្រ (កម្មន្តសាល-វាយនភណ្ឌ និងសម្លៀកបំពាក់មាន ៨១០ រោងចក្រ និងមានពលករបម្រើការងារ ៥៩៤.៣២៣ នាក់) និងមានរោងចក្របិទទ្វាឈប់ដំណើរការផលិតកម្មមានចំនួន ១៤៨ រោងចក្រ (រោងចក្រកាត់ដេរ ចាក់ មានចំនួន ៧៦ រោងចក្រ) និងប៉ះពាល់កម្លាំងពលកម្ម ៨០.៥៦៩នាក់ ។

❋ អង្គភាពរដ្ឋាករទឹកសាធារណៈ និងរដ្ឋាករទឹកឯកជនទូទាំងប្រទេសផលិតបានសរុបចំនួន ៤០៣.៦២២.៥៧០មៈ បើធៀបនឹងឆ្នាំមុនមានចំនួន ៣៧៧.០៣២.៣២១មៈ កើនឡើង ២៦.៥៩០.២៤៩ មៈ ស្មើនឹង ៧,០៥% ក្នុងនោះ រដ្ឋាករទឹកស្វយ័តរាជធានីភ្នំពេញផលិតទឹកស្អាតបានចំនួន ២៤៤.៥៩៦.០០៥មៈ ស្មើនឹង១០៧,២៧% នៃផែនការ ដែលមានចំនួន ២២៧.៩៦០.៣៥៨មៈ ដោយបានចំណូលសរុប ១៥៤.៣៧៣.១៨៨.៤៩៤ រៀល ស្មើនឹង ៤៥,៤៤%នៃផែនការដែលមាន ៣៣៩.៧១៦.៧៨៩.០០០រៀល, រដ្ឋាករទឹកស្វយ័តខេត្តសៀមរាប ផលិតទឹកស្អាតបានចំនួន ៥.៩៦៨.៤៣២មៈ ស្មើនឹង ៨៨% នៃផែនការ ដែលមាន៦.៧៥៣.៧៨០មៈ ដោយបានចំណូលសរុប ១២.៥៩៣.៩៩៣.៣៨៩ រៀល ស្មើនឹង ៩៣%នៃផែនការ ដែលមាន ១៣.៥៧០.៥៤៥.៧០០រៀល និងរដ្ឋាករទឹកសាធារណៈ និងឯកជនទូទាំងប្រទេសក្រៅពីរាជធានីភ្នំពេញ និងសៀមរាបផលិតទឹកស្អាតបានចំនួន ១៥៣.០៥៨.១៣៣មៈ បើធៀបនឹងឆ្នាំមុន ១៣៧.៩៧៧.៨៦៨មៈ កើនឡើង ១៥.០៨០.២៦៥មៈ ស្មើនឹង ១០,៩៣% ។

❋ ប្រជាពលរដ្ឋទទួលបានការងារធ្វើថ្មី ១៤៣.៣៧១ នាក់ (ស្រី ៩៩.៦៣៦ នាក់) ក្នុងនោះការងារក្នុងប្រទេសមានចំនួន ១៤០.០៩០ នាក់ (ស្រី ៩៨.៥៥៤ នាក់) និងបញ្ជូនទៅធ្វើការនៅក្រៅប្រទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន និងគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (គ.ប.ប.ព.ប) មាន ៣.២៨១ នាក់ (ស្រី ១.០៨២ នាក់) រួមមាន សាធារណរដ្ឋកូរ៉េ ២.៥៧៧ នាក់ (ស្រី ៧០១នាក់) ប្រទេសជប៉ុន ៦៣១ នាក់ (ស្រី ៣០៨ នាក់) ប្រទេសសិង្ហបូរី ៣ នាក់ (ស្រី) និងតំបន់រដ្ឋបាលពិសេសហុងកុង ៧០ នាក់ (ស្រី)។ គិតត្រឹមឆ្នាំ ២០២១នេះ ពលករកម្ពុជាដែលបានស្នាក់នៅ និងធ្វើការនៅបរទេសសរុបមាន ១.៣០១.៦០៩ នាក់ (ស្រី ៥២៨.៧៩៩នាក់) រួមមាន ប្រទេសថៃ ចំនួន ១.២២០.១៩៧ នាក់ (ស្រី ៤៨៩.៧១៣ នាក់) សាធារណរដ្ឋកូរ៉េ ចំនួន ៤៥.៨៦៦ នាក់ (ស្រី ១០.៤៧៤នាក់) ម៉ាឡេស៊ី ចំនួន ២៣.០២៧ នាក់ (ស្រី ២២.០៦៩ នាក់) ជប៉ុន ចំនួន ១១.៤៥៣ នាក់ (ស្រី ៥.៤៧៧ នាក់) តំបន់រដ្ឋបាលពិសេសហុងកុង ពលការិនី ចំនួន ៨២១ នាក់ និងប្រទេសអារ៉ាប៊ីសាអូឌីត ពលការិនីចំនួន ៤៣ នាក់ ៕

"ការយោសនាបោះឆ្នោត" សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ ២០២២

១.ការយោសនាបោះឆ្នោត គឺមានបំណងឲ្យគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះ បោះឆ្នោត និងបេក្ខជន ធ្វើការផ្សព្វផ្សាយអំពីគោលនយោបាយ និងកម្មវិធីនយោបាយរបស់ខ្លួន ដើម្បីបញ្ចុះបញ្ចូលឲ្យប្រជាពលរដ្ឋជាម្ចាស់សន្លឹកឆ្នោតបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សរបស់ខ្លួន ។

- សកម្មភាព និងរូបភាពយោសនាបោះឆ្នោត រួមមាន ៖ ការជួបជុំជាសាធារណៈរបស់គណបក្ស ឬ បេក្ខជន ការរៀបចំក្បួនព្យុហយាត្រាដោយថ្មើរជើងឬដោយយានជំនិះគ្រប់ប្រភេទនៅឃុំសង្កាត់យ៉ាងច្រើន ២ដង ការជួបជុំឬការយោសនាតាមផ្ទះ ការផ្សព្វផ្សាយតាមវិទ្យុទូរទស្សន៍ សារព័ត៌មាន ឬតាមឧបករណ៍បំពងសំឡេង ឬតាមការចាក់ផ្សាយជាវីដេអូ ការបិទផ្សាយ និងលើកបដាយោសនានៅទីសាធារណៈ ឬឯកជន ការចែកខិត្តប័ណ្ណគណបក្ស សញ្ញាគណបក្ស មួក សម្លៀកបំពាក់ និងសម្ភារផ្សេងៗទៀតមានរូបសញ្ញាគណបក្ស ឬបេក្ខជន ការប្រគំតន្ត្រី និងការប្រកួតកីឡា ដើម្បីផ្សព្វផ្សាយការគាំទ្រគណបក្ស ឬបេក្ខជនណាម្នាក់ ។

- យោងតាមផែនការណែនាំរួមឆ្ពោះទៅកាន់ការបោះឆ្នោត ថ្នាក់កណ្តាល ត្រូវរៀបចំខ្លឹមសារ និងផលិត ឯកសារពាក់ព័ន្ធការយោសនាសម្រាប់ចែកជូនដល់គ្រប់ឃុំ សង្កាត់ភូមិ ។នៅគ្រប់ស្នាក់ការគណបក្សត្រូវកែលម្អ មានចងបដាពាក្យស្លោក និងចាក់មីក្រូផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សក្នុងការអភិវឌ្ឍឃុំ សង្កាត់ និងសាររបស់ថ្នាក់ដឹកនាំគណបក្សឲ្យបានកងរំពង និងត្រូវមានអ្នកប្រចាំការរាល់ថ្ងៃ ២៤ម៉ោង ដើម្បីបញ្ជាដឹកនាំដោះស្រាយរាល់បញ្ហានានាដែលកើតឡើង និងត្រួតពិនិត្យណែនាំការងារជាក់ស្តែង ។ ក្រុមការងារ និងគណបក្សគ្រប់ថ្នាក់ ព្រមទាំងបេក្ខជន និងកម្លាំងសរុបរបស់គណបក្ស ត្រូវរួមគ្នាចេញធ្វើការយោសនា ឲ្យដល់ចំណុចកំពូល មានទាំងការដង្ហែក្បួនចំនួន ២ដង និងត្រូវធ្វើឲ្យបានព្រមៗគ្នានៅតាមទីកន្លែងសាធារណៈ ទីកន្លែងឯកជន ដែលបានកំណត់ និងមានការអនុញ្ញាតត្រឹមត្រូវតាមផ្ទះ ឬតាមគ្រួសារ ឬតាមការជួបផ្ទាល់ ។

២.ការយោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៥ ឆ្នាំ ២០២២ មានរយៈពេល ១៤ថ្ងៃ ចាប់ពីថ្ងៃទី ២១ ខែឧសភា ដល់ថ្ងៃទី ៣ ខែមិថុនា ឆ្នាំ ២០២២ ហើយគ្រប់សកម្មភាពយោសនាត្រូវបញ្ឈប់ ២៤ម៉ោង មុនថ្ងៃបោះឆ្នោត ។ គ្រប់សកម្មភាពយោសនាត្រូវចាប់ផ្តើមពីម៉ោង ៦ព្រឹក ដល់ម៉ោង ១០យប់ និងឈប់សម្រាកចន្លោះពីម៉ោង ១០យប់ ដល់ម៉ោង ៦ព្រឹក លើកលែងតែសកម្មភាព យោសនាដោយឧបករណ៍បំពងសំឡេងត្រូវហាមឃាត់ចាប់ពីម៉ោង ១២ថ្ងៃត្រង់ ដល់ម៉ោង ២រសៀល និងហាមឃាត់នៅក្បែរមន្ទីរពេទ្យ សាលារៀន ឬគ្រឹះស្ថានសិក្សានានាក្នុងពេលម៉ោងសិក្សា ។

៣. គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត មានសិទ្ធិលើកស្លាកសញ្ញា គណបក្ស ឬបិទផ្សាយឯកសារយោសនាបោះឆ្នោតនៅទីសាធារណៈ ឬនៅទីស្នាក់ការរបស់ខ្លួន ឬទីកន្លែង ឯកជនក្នុងកំឡុងពេលយោសនាបោះឆ្នោត ។ ការលើក ឬបិទនៅទីសាធារណៈត្រូវមានការសម្របសម្រួល ពីអាជ្ញាធរឃុំ សង្កាត់ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសោភ័ណភាព សាធារណៈ និងនៅកន្លែងឯកជនត្រូវមានការយល់ព្រមជាមុនពីម្ចាស់កន្លែង ។ ស្លាកសញ្ញា និងសម្ភារយោសនា របស់គណបក្សនយោបាយ មិនអនុញ្ញាតឲ្យលើក ឬបិទនៅបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។

៤. គណបក្សនយោបាយអាចហែក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះ គ្រប់ប្រភេទបានយ៉ាងច្រើន ២ដង ក្នុងក្របខណ្ឌព្រំប្រទល់ឃុំ សង្កាត់ ដែលគណបក្សមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ មិនអនុញ្ញាតឲ្យឆ្លងឃុំ សង្កាត់ឡើយ ។ ក្នុងករណីមានបំណងហែក្បួនឆ្លងកាត់ ឃុំ សង្កាត់ពីរ ឬច្រើនដែលមានព្រំប្រទល់ជាប់គ្នា ដែលគណបក្សនយោបាយមានបញ្ជីបេក្ខជនឈរឈ្មោះត្រូវ ជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គយ.សប ពាក់ព័ន្ធយ៉ាងហោចឲ្យបាន ៣ថ្ងៃមុនថ្ងៃហែក្បួនយោសនា ។ ឃុំ សង្កាត់ពាក់ព័ន្ធដែលគណបក្សនយោបាយបានហែក្បួនឆ្លងកាត់នោះត្រូវចាត់ទុកថា បានហែក្បួនមួយ ដងរួចហើយ ។

៥.ទម្រង់និងទំហំកំណត់ជាការហែក្បួនព្យុហយាត្រាឬក្បួនដំណើរដោយថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ គឺជាការរៀបចំជាក្បួនមានបិទបដា ឬពាក្យស្លោក ឬសារនយោបាយផ្សេងៗភ្ជាប់នឹងរថយន្ត ឬទោចក្រយានយន្ត ឬត្រីចក្រយានយន្ត ឬជលយានគ្រប់ប្រភេទ និងមានការចាក់ផ្សាយដោយឧបករណ៍បំពងសំឡេង មានអ្នកចូលរួមចាប់ពី ២០នាក់ឡើងទៅ ដោយប្រើប្រាស់រថយន្តចាប់ពី ២គ្រឿងឡើងទៅ អមដោយទោចក្រយានយន្ត ឬត្រីចក្រយានយន្តចាប់ពី ១០គ្រឿងឡើងទៅ ប្រើប្រាស់ទោចក្រយានយន្ត ឬត្រីចក្រយានយន្តចាប់ពី ២០គ្រឿង និងប្រើប្រាស់ជលយានគ្រប់ប្រភេទចាប់ពី ៥គ្រឿងឡើងទៅ ។

៦. គណបក្សនយោបាយដែលមានបំណងហែក្បួនយោសនាបោះឆ្នោត ត្រូវជូនដំណឹងជាលាយលក្ខណ៍ អក្សរទៅ គយ.សប យ៉ាងហោចឲ្យបាន ៣ថ្ងៃមុនថ្ងៃហែក្បួនយោសនា ។ ការជូនដំណឹងត្រូវបញ្ជាក់ឲ្យបានច្បាស់ឈ្មោះ និងអាសយដ្ឋានអចិន្ត្រៃយ៍របស់តំណាងគណបក្ស កាលបរិច្ឆេទ និងពេលវេលានៃការហែក្បួន ទីតាំងប្រមូលផ្តុំ និងតម្រាយផ្លូវដែលត្រូវហែក្បួន ចំនួនអ្នកចូលរួម និងចំនួនយានជំនិះតាមប្រភេទនីមួយៗ ។

៧. មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋគ្រប់ប្រភេទដែលប្រើប្រាស់ស្លាកសញ្ញារាជការ រដ្ឋ នគរបាល ខេមរភូមិន្ទ និងរាជរដ្ឋាភិបាល ទោះដោះស្លាកលេខចេញ មិនត្រូវបានអនុញ្ញាតឲ្យយកមកធ្វើសកម្មភាពយោសនាបោះឆ្នោត ឬដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់

តទៅទំព័រទី ២៨

ធនាគារជាតិនៃកម្ពុជាកំណត់គោលនយោបាយចម្បងៗ ដើម្បីគាំទ្រការងើបឡើងនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព

*ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២*

ធនាគារជាតិនៃកម្ពុជាបានបង្ហាញថា សេដ្ឋកិច្ចកម្ពុជានៅឆ្នាំ២០២១ មានភាពល្អជាងឆ្នាំ២០២០ ដែលគាំទ្រដោយការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកដែលបានជួយជំរុញការនាំចេញ គួបផ្សំនឹងការអនុវត្តប្រកបដោយប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលនូវវិធានការគាំទ្រសេដ្ឋកិច្ច វិធានការគ្រប់គ្រងការឆ្លងរាលដាលនៅក្នុងសហគមន៍ និងការសម្រេចចាក់វ៉ាក់សាំងដល់ប្រជាជនបានប្រមាណ ៩០% នៃប្រជាជនសរុប ដែលបានបើកឱ្យសកម្មភាពសេដ្ឋកិច្ចដំណើរការឡើងវិញជាលំដាប់។

ឆ្នាំ២០២១ កន្លងទៅធនាគារជាតិនៃកម្ពុជាបានធ្វើអន្តរាគមន៍លើទីផ្សារប្តូរប្រាក់ តាមរយៈការលក់ប្រាក់ដុល្លារអាមេរិកជាង ៥០០ លាន ដើម្បីស្រូបយកប្រាក់រៀលពីសេដ្ឋកិច្ច និងរក្សាអត្រាប្តូរប្រាក់ទីផ្សារឱ្យមានស្ថិរភាពក្នុងរង្វង់ ៤.០៩៩ រៀលក្នុងមួយដុល្លារអាមេរិក។ ការបន្តដាក់ចេញវិធានការបុរេសកម្មនានា ជាពិសេស ការបន្តការបន្ធូរបន្ថយបទប្បញ្ញត្តិ និងការអនុវត្តនយោបាយរូបិយវត្ថុវិស្តារកម្ម ដែលផ្តល់លទ្ធភាពឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមានសាច់ប្រាក់គ្រប់គ្រាន់ សម្រាប់ពង្រឹងស្ថានភាពដើមទុន និងលើកកម្ពស់សមត្ថភាពគ្រប់គ្រងហានិភ័យ ប្រកបដោយប្រសិទ្ធភាព ព្រមទាំងបន្តអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ផ្តល់ការអនុគ្រោះរៀបចំឥណទានឡើងវិញ សរុបចំនួន ៣៧០.៧៨៥ គណនី ស្មើនឹង ២២,៤ ទ្រីលានរៀល (៥,៥ ប៊ីលានដុល្លារអាមេរិក) ដែលបានសម្រាលបន្ទុករបស់ប្រជាពលរដ្ឋនិងអាជីវកម្មបានមួយកម្រិត។

ស្របតាមដំណើរការសេដ្ឋកិច្ចនិងការរស់នៅតាមគន្លងថ្មី ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍន៍ និងអនុញ្ញាតឱ្យប្រើប្រាស់ប្រព័ន្ធទូទាត់អេឡិចត្រូនិកដែលបានសម្រួលដល់ការទូទាត់ និងការផ្ទេរប្រាក់ក្នុងប្រតិបត្តិការពាណិជ្ជកម្ម និងវិនិយោគទាំងក្នុងនិងក្រៅប្រទេស។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានពង្រឹងជាប្រចាំនូវការអនុវត្តច្បាប់បទប្បញ្ញត្តិ និងកាតព្វកិច្ចនានាពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មរបស់បុគ្គលរាយការណ៍។

ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងកំពុងវិវត្តទៅរកការទូទាត់ឌីជីថល ដែលមានហេដ្ឋារចនាសម្ព័ន្ធសេវា និងឧបករណ៍ទូទាត់ថ្មីៗ។ ក្នុងឆ្នាំ២០២១ ការទូទាត់អេឡិចត្រូនិកបានកើនឡើងធៀបនឹងឆ្នាំ២០២០ ដោយប្រតិបត្តិការទូទាត់អេឡិចត្រូនិកមានចំនួន ៦៩៨,៨ លានប្រតិបត្តិការ (គិតជាទឹកប្រាក់ ១៩៩,៧៦ ប៊ីលានដុល្លារអាមេរិកស្មើនឹង ៧៨៧% នៃផលិតផលសរុប)។ ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យាហិរញ្ញវត្ថុ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមួយចំនួនបានដាក់ឱ្យ ប្រើប្រាស់សេវាផ្ទេរប្រាក់និងទូទាត់ឆ្លងដែនតាមរយៈមធ្យោបាយឌីជីថលបន្ថែមពីលើការផ្តល់សេវាតាមគ្នាក់ងារនិងបញ្ជរ។

ក្រដាសប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកត្រូវបានផ្គត់ផ្គង់ ដើម្បីគាំទ្រការរីកចម្រើនក្នុងតំបន់ នៅទូទាំងប្រទេសតាមរយៈសាខារាជធានី-ខេត្ត ធនាគារជាតិនៃកម្ពុជា ដល់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងក្រសួងមន្ទីររបស់រាជរដ្ឋាភិបាល។ ក្រដាសប្រាក់ដែលធនាគារជាតិនៃកម្ពុជាទទួលបានពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ត្រូវបានរាប់ជ្រើសរើសដោយកាត់កម្ទេចចោលនូវក្រដាសប្រាក់រៀល ចាស់ ទក់រហែក និងដាក់ទៅក្នុងចរាចរណ៍នូវក្រដាសប្រាក់ដែលមានគុណភាពល្អ និងបានសម្លាប់មេរោគហើយ។

ក្នុងសន្និបាតបូកសរុបលទ្ធផលការងារធនាគារជាតិនាពេលកន្លងមក ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជាបានលើកឡើងថា នៅឆ្នាំ២០២២ ការលេចឡើងនៃមេរោគកូវីដបំប្លែងថ្មីៗបានបន្តគំរាមកំហែងដល់ ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកនិងតំបន់ដែលអាចបន្តយអត្រាកំណើនឱ្យទាបជាងការរំពឹងទុក។ ស្ថានភាពបានដាក់សម្ពាធដល់ការងើបឡើងនៃសេដ្ឋកិច្ចកម្ពុជាជាពិសេសផលប៉ះពាល់លើវិស័យទេសចរណ៍ការរំខានដល់ខ្សែច្រវាក់ដឹកជញ្ជូននាំចេញ-នាំចូលទំនិញ និងកំណើនយឺតនៃលំហូរវិនិយោគបរទេស ។ ទោះយ៉ាងណា ការងើបឡើងនៃសេដ្ឋកិច្ចពិភពលោកនឹងបន្តគាំទ្រ ការនាំចេញវិស័យកាត់ដេរនិងកម្មន្តសាលមិនមែនកាត់ដេរ ដូចជា គ្រឿងបង្គុំអគ្គិសនីនិងកង់ ។ ការគ្រប់គ្រងបានលើការរាលដាលជំងឺកូវីដ-១៩ និងការបន្តបើកដំណើរការសេដ្ឋកិច្ចនឹងជំរុញសកម្មភាពសេដ្ឋកិច្ចដូចជា ពាណិជ្ជកម្ម ការវិនិយោគ ការដឹកជញ្ជូននិងទូរគមនាគមន៍ និងទេសចរណ៍ក្នុងស្រុក។ ជាមួយគ្នានេះ វិស័យកសិកម្មរំពឹងថា នឹងបន្តមានកំណើនល្អ ដែលគាំទ្រដោយគោលនយោបាយគាំពាររបស់រាជរដ្ឋាភិបាល និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់និងទ្វេភាគី។ ក្រោមការរំពឹងទុកដោយសុទិដ្ឋិនិយមនេះ កំណើនសេដ្ឋកិច្ចកម្ពុជានាឆ្នាំ២០២២ ត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រា ៥%។

ដើម្បីគាំទ្រការងើបឡើងនៃកំណើនប្រកបដោយចីរភាព រាជរដ្ឋាភិបាលដាក់ចេញនូវក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ច ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី ដែលមានគោលដៅស្តារ កែទម្រង់ និងពង្រឹងភាពធន់នៃសេដ្ឋកិច្ច។ ស្របតាមទិសដៅនេះ ធនាគារជាតិនៃកម្ពុជា ក៏ដូចជាប្រព័ន្ធធនាគារ

ដើម្បីបំពេញតម្រូវការ និងផ្តល់ភាពងាយស្រួលជូនដល់អតិថិជន ធនាគារបានដាក់ដំណើរការម៉ាស៊ីនអេធីអឹម

កម្ពុជានឹងបន្តដាក់ចេញគោលនយោបាយចម្បង។ ដូចខាងក្រោម៖

ទី១- ការរក្សាស្ថិរភាពអត្រាប្តូរប្រាក់៖ ស្ថិរភាពអត្រាប្តូរប្រាក់នឹងបន្តរួមចំណែកយ៉ាងសំខាន់ដល់ការរក្សាស្ថិរភាពថ្លៃនិងការពារអំណាចទិញនៃប្រាក់រៀល ក៏ដូចជាចំណូលរបស់ប្រជាពលរដ្ឋ។ គួររំលេចថា អត្រាប្តូរប្រាក់នៅឆ្នាំ២០២២ នេះនឹងអាចបន្តរងសម្ពាធធ្លាក់ថ្លៃ ដោយសារការអនុវត្តវិធានការគាំទ្រដែលបញ្ចេញប្រាក់ទៅលើទីផ្សារគួបផ្សំនឹងនិន្នាការឡើងថ្លៃនៃប្រាក់ដុល្លារអាមេរិក ជាពិសេសបណ្តាលមកពីការរំពឹងទុកលើការធ្វើប្រក្រតីកម្មនយោបាយរូបិយវត្ថុរបស់ ធនាគារកណ្តាលសហរដ្ឋអាមេរិកនាពេលខាងមុខ។ ក្នុងស្ថានភាពនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ដើម្បីរក្សាអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកឱ្យមានស្ថិរភាពក្នុងកម្រិតសមស្របតាមស្ថានភាពសេដ្ឋកិច្ច។

ទី២- ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀល៖ វិបត្តិកូវីដ-១៩ បានបង្ហាញយ៉ាងច្បាស់ពីតួនាទី មិនពេញលេញនៃនយោបាយរូបិយវត្ថុក្នុងការជួយគាំទ្រសេដ្ឋកិច្ច ដូចជា លទ្ធភាពបន្ថយអត្រាការប្រាក់ដើម្បីជំរុញការវិនិយោគ ឬការប្រើប្រាស់ ដោយសារតែកម្រិតខ្ពស់នៃដុល្លារូបនីយកម្ម។ ដូច្នេះ ការលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅតែបន្តជាការងារអាទិភាពចម្បង ក្នុងការពង្រឹងប្រសិទ្ធភាព អធិបតេយ្យ និងឯករាជ្យនៃនយោបាយរូបិយវត្ថុ សំដៅគាំទ្រកាន់តែសកម្មក្នុងដំណើរការស្តារ និងពង្រឹងភាពធន់នៃ សេដ្ឋកិច្ច។ ក្នុងទិសដៅនេះ ធនាគារជាតិនៃកម្ពុជាបាន និងកំពុងចូលរួមគាំទ្រការបោះផ្សាយមូលបត្ររដ្ឋជាប្រាក់រៀល ដែលមិនត្រឹមតែជាប្រភពហិរញ្ញប្បទានរយៈពេលវែងសម្រាប់ការវិនិយោគសាធារណៈប៉ុណ្ណោះទេ តែថែមទាំងជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល ក៏ដូចជាការបង្កើតឧបករណ៍នយោបាយរូបិយវត្ថុថ្មីផ្អែកលើយន្តការទីផ្សារផងដែរ។

ទី៣- ការអនុវត្តវិធានការគាំទ្រចំគោលដៅ៖ ដោយសារការងើបឡើងនៃវិស័យសេដ្ឋកិច្ចមានល្បឿន ខុសគ្នា ដូច្នេះ ការអនុវត្តវិធានការគាំទ្រនឹងត្រូវធ្វើឡើងឱ្យចំគោលដៅ ចំពោះវិស័យទ្រទ្រង់កំណើន ។ ក្នុងន័យនេះ ប្រព័ន្ធធនាគារនឹងចូលរួមចំណែកគាំទ្រការស្តារវិស័យអាទិភាពតាមរយៈការបន្ធូរបន្ថយ បទប្បញ្ញត្តិសមស្របនិងអាស្រ័យលើកម្រិតហានិភ័យ។ទន្ទឹមនេះធនាគារជាតិនៃកម្ពុជាក៏នឹងអនុវត្តយុទ្ធសាស្ត្រចាកចេញពីវិបត្តិ (Exit Strategy) ដែលនឹងត្រូវធ្វើឡើងតាមដំណាក់កាល ប្រកបដោយភាពប្រុងប្រយ័ត្ននិងស្របតាមការវិវត្តនៃស្ថានភាពសេដ្ឋកិច្ចជាក់ស្តែង ដោយគិតគូរយ៉ាងល្អិតល្អន់ពីហានិភ័យចិត្តសាស្ត្រ (Moral Hazard) និងស្ថិរភាពប្រព័ន្ធធនាគារ។

ទី៤- ការលើកកម្ពស់បរិយាបន្ន និងចំណេះដឹងហិរញ្ញវត្ថុ៖ បច្ចុប្បន្នការទទួលបានសេវាហិរញ្ញវត្ថុដែលមានតម្លៃសមស្រប នៅមានកម្រិតនៅឡើយដែលជាឧបសគ្គមួយក្នុងការរួមចំណែកអភិវឌ្ឍ សហគ្រាសធុនតូចនិងមធ្យម ដែលជាឆ្អឹងខ្នងនៃសេដ្ឋកិច្ច។ ក្នុងស្ថានភាពនេះ យុទ្ធសាស្ត្រជាតិស្តីពីបរិយាបន្នហិរញ្ញវត្ថុ នឹងបន្តជាមគ្គុទ្ទេសក៍ក្នុងការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ សម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងភាគីពាក់ព័ន្ធនានា។ ជាមួយគ្នានេះ ចំណេះដឹងផ្នែកហិរញ្ញវត្ថុក៏នឹងត្រូវបន្តពង្រឹងជាប្រចាំ តាមរយៈការបញ្ចូលទាំងក្នុងកម្មវិធីសិក្សានិងយុទ្ធនាការផ្សព្វផ្សាយនានាទៅលើការប្រើប្រាស់លុយវប្បធម៌ឥណទាន និងការសន្សំ។

ទី៥- សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្តទាំងអស់ត្រូវបន្តគាំទ្រការកែចម្រើនសេដ្ឋកិច្ចក្នុងតំបន់ តាមរយៈការផ្តល់សេវាគ្រប់គ្រងសាច់ប្រាក់ ប្រកបដោយភាពសកម្មនិងប្រសិទ្ធភាព និងរួមចំណែកលើកកម្ពស់ចំណេះផ្នែកហិរញ្ញវត្ថុនិងកិច្ចការពារអតិថិជន តាមរយៈប្រព័ន្ធ Hotline ដើម្បីផ្តល់ព័ត៌មាន និងជួយដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងការប្រើប្រាស់សេវាហិរញ្ញវត្ថុជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះ សាខាក៏ត្រូវបន្តសហការ និងគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល សំដៅពង្រឹងតម្លាភាពនិងគណនេយ្យភាពនៃប្រតិបត្តិការគ្រប់គ្រងសាច់ប្រាក់។

